# របាំគោះអង្រែ

# Pestle Dance



ឧបត្ថម្ភថវិកាដោយអង្គការយូណេស្កូ

www.elibraryofcambodia.org

Le
792
PES

# របាំគោះអង្រែ

# Pestle Dance

ព្រះរាជាណាចក្រកម្ពុជា
1640/04
3/1
បណ្ណាល័យជាតិ

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យជាតិ

ឧបត្ថម្ភថវិកាដោយអង្គការយូណេស្កូ

បោះពុម្ពលើកទី១ ចំនួន ១០០០ ច្បាប់

ខែតុលា ឆ្នាំ២០០៣

National Library of Cambodia
00016090

www.elibraryofcambodia.org



ព្រឹទ្ធាចារ្យ ឆេង ផុន



ព្រឹទ្ធាចារ្យ ហង់ ជួន



ព្រឹទ្ធាចារ្យ ពេជ្រ ធុំក្រវិល



សាស្ត្រាចារ្យ ហង្ស សុត



សាស្ត្រាចារ្យ ហ៊ុន សាវិន

www.elibraryofcambodia.org

# មាតិការឿង
# Contents


១ - សេចក្ដីថ្លែងអំណរគុណ..........................................៨

Acknowledgement 9

២ - បុព្វកថា..........................................................១០

Foreword 11

៣ - ឧទ្ទិស............................................................១២

Dedication 13

៤ - អារម្ភបទ.........................................................១៤

Preface 15

៥ - ប្រវត្តិរបាំគោះអង្រែ..............................................១៦

Background of Pestle dance 17

៦ - វង់ភ្លេងមហោរី....................................................១៨

Mohori ensemble 19

៧ - ឧបករណ៍របាំ......................................................២០

Dance instruments 20

៨ - ឧបករណ៍ភ្លេង.....................................................២១

Musical instruments 21

៩ - សំលៀកបំពាក់.....................................................២៣

Dance Costumes 23

១០ - វគ្គ និងក្បាច់របាំ.................................................៣១

Main Chapter of dance 31

១១ - ក្រឡារបាំ........................................................១០២

Diagram of dance movements 102

១២ - បទចម្រៀង និង អក្សរភ្លេង...................................១៣៦

Songs and musical score 136


www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណជាពន្លឺកចំពោះអង្គការយូណេស្កូ ដែលបានជួយឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹង និងផ្តល់ឱកាសឱ្យក្រុមស្រាវជ្រាវយើងអាចចងក្រងឯកសារនេះឡើងដើម្បីជួយរក្សាមតិកសិល្បះខ្មែរ ប្រែក្លាយ ជាព្រលឹងរស់ហើយឋិតក្នុងសន្ដានចិត្តកូនខ្មែរជានិរន្តរ៍ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកព្រឹទ្ធាចារ្យ **ឆេង ផុន**, ឯកឧត្តម **ពេជ្រ ទុំក្រវិល**, ឯកឧត្តម **ហង្ស សុត**, សាស្ត្រាចារ្យ **ហ៊ុន សារិន** និងលោក **ប្រៀត ប្រ៊ឹមចឹក** ដែលបានផ្តល់ដំបូន្មានល្អក្នុងការជួយស្ថាបនាឱ្យស្នាដៃនេះកាន់តែមានសុក្រិតភាពល្អថែមទៀត ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកគ្រូ អ្នកគ្រូ និង សិល្បករទាំងអស់ដែលបានរួមចំណែក ផ្តល់យោបល់ក្នុងការចងក្រងសៀវភៅរបាំប្រពៃណីនេះ ទុកជាប្រយោជន៍ដល់កូនខ្មែរដែលកំពង់ក្រេបរស់ជាតិវិជ្ជាសិល្បៈវប្បធម៌ខ្លួន ដើម្បីឈានឆ្ពោះទៅរកឧត្តមភាពជាតិ ថែមមួយកម្រិតទៀត ពិសេសលើឆាកអន្តរជាតិ ។



www.elibraryofcambodia.org

# Acknowledgements

We would proudly like to thank UNESCO for supporting this publication, which will contribute to the documentation and preservation of Khmer Culture heritage.

Also, we would like to thank our eminent Professor Chheng Phonh and HE Pich Tum Kravel, HE Hang Soth, Professor Hun Sarin and Mr. Fred Frumberg as well as the teachers and artists who provided relevant comments and assisted in this importand publication.



www.elibraryofcambodia.org

# បុព្វកថា

អង្គការយូណេស្កូ មានកិត្តិយសដែលបានរួមវិភាគទាន ក្នុងជោគជ័យនៃការបោះពុម្ព សៀវភៅរបាំប្រពៃណីខ្មែរដ៏សំខាន់មួយគឺ "របាំគោះអង្រែ" ។ សមិទ្ធផលនៃឯកសារនេះជាសក្ខីភាព ផ្តល់នូវកិច្ចខំប្រឹងប្រែងពីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈលើកិច្ចស្តារឡើងវិញ និងថែរក្សា ការពារមតិកវប្បធម៌អរូបីដ៏មានតម្លៃរបស់ប្រទេសនេះ ហើយជាពិសេសរបាំប្រពៃណីដែលមានចរិតផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋខ្មែរ ។

ដោយខ្សែករបាំប្រពៃណី និងនិយាយជារូមសិល្បៈទស្សនីយភាព គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការនាំមកនូវគ្រប់ភាគីក្នុងសង្គមខ្មែរ ដើម្បីការពារអត្តសញ្ញាណវប្បធម៌ជាតិ ។ ទម្រង់សិល្បៈប្រពៃណីជាច្រើនក្នុងពេលកន្លងមកត្រូវបានបាត់បង់ និងដោយហោចណាស់កំពុង ប្រឈមមុខនឹងគ្រោះថ្នាក់នេះ។ ហេតុផលនេះហើយ អង្គការយូណេស្កូមានបីតិរីករាយសាទរ ចំពោះអ្នកស្រាវជ្រាវព្រមទាំងសិល្បករសិល្បការិនី នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលបានប្រឹងប្រែងប្រមូលចងក្រងក្បួនខ្នាត និងផ្សព្វផ្សាយនូវសិល្បៈប្រពៃណីដ៏ល្អឯកនេះ។

អង្គការយូណេស្កូ សូមផ្តល់ការលើកទឹកចិត្តដល់ស្ថាប័នស្រាវជ្រាវជាតិ លើការបង្កើតវិធីសាស្ត្រថ្មីក្នុងបំណងការពារ និងអភិរក្សទាំងសិល្បៈប្រពៃណី និងប្រជាប្រិយ ជាពិសេសតាមរយៈការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រទំនើប ។ អង្គការយូណេស្កូត្រៀមជាស្រេចក្នុងការបន្តផ្តល់កិច្ចសហការគាំទ្ររាជរដ្ឋាភិបាលលើកិច្ចខិតខំខ្លែង ដើម្បីផលប្រយោជន៍អនាគតខេមរជន ។

សូមប្រសិទ្ធពរជ័យ សូមបានប្រកបដោយអាយុ វណ្ណ សុខ ពល ។

លោក អេរីជេន ក្លេម៉ង់

អ្នកតំណាងអង្គការយូណេស្កូប្រចាំនៅកម្ពុជា



www.elibraryofcambodia.org

# FOREWORD

UNESCO is very honoured to have contributed to the successful publication of this important book about one of the most characteristic forms of traditional dances in Cambodia, the *Robam Angré* (Pestle Dance). The completion of this publication bears testimony to the continuous efforts of the Ministry of Culture and Fine Arts to preserve and revitalise the precious cultural intangible heritage of the country, and particularly the traditional dances that resemble the daily lives of ordinary Cambodian citizens.

Traditional dance in particular and performing arts in general constitute a powerful instrument to bring together all social groups in Cambodia and assert the national cultural identity. Many of these traditional forms have been lost however in previous years or face the risk of disappearing. For this reason, UNESCO is particularly grateful to the researchers and artists of the Ministry of Culture and Fine Arts who have made possible the documentation and dissemination of this unique traditional dance.

UNESCO would also like to encourage the national institutions to take new measures aiming at the safeguarding of traditional dance and folklore, especially through the promotion of scientific research in this field. UNESCO is ready to continue to provide its assistance to the Royal Government for this endeavor in the benefit of future Cambodian generations.



Etienne Clément,
UNESCO Representative in Cambodia



www.elibraryofcambodia.org

# ឧទ្ទិស

យើងខ្ញុំជាសិល្បករ សិល្បការិនីទាំងអស់ សូមឧទ្ទិសស្នាដៃរបាំពោះអង្រែនេះ ជូនចំពោះមហាវីរបុរស សិល្បករ សិល្បការិនី លោកគ្រូ អ្នកគ្រូគ្រប់ជំនាន់ ដែលមានចិត្តស្រលាញ់ អង់អាចក្លាហានឆ្លាតវាងវៃ ដើម្បីកសាងស្នាដៃផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយ រហូតមកទល់សព្វថ្ងៃនេះ ។

សូមគោរពដល់ វិញ្ញាណក្ខន្ធលោក ព្រឹទ្ធាចារ្យ **ម៉ុល សំអឿន** ដែលលោកបានចែករំលែកបទពិសោធន៍ក្នុងរបបប៉ុលពត លោកបានបន្សល់ទុក នូវស្នាដៃរបាំប្រពៃណីជាច្រើន ជាពិសេសរបាំពោះអង្រែនេះ ។ សូមគោរពដល់ដួងព្រលឹង មហាវីរបុរស សិល្បករ សិល្បការិនីទាំងអស់ដែលបាន ពលីជីវិតក្នុងបុព្វហេតុកសាងអារ្យធម៌ និងវប្បធម៌ដ៏គួរស្ញប់ស្ញែងជាទីគោរពសក្ការៈទុកដល់កូនចៅជំនាន់ក្រោយ និងសូមវិញ្ញាណក្ខន្ធ អស់លោកដ៏មានគុណទាំងអស់ទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

យើងខ្ញុំសង្ឃឹមថាស្នាដៃនេះ នឹងបានជាប្រយោជន៍ដល់កុលបុត្រ កុលធីតា អ្នកសិក្សាស្រាវជ្រាវទាំងឡាយ ទុកជាមតិកដ៏សំខាន់មួយជូនជនានុជន ជាតិខេមរា រក្សាឃុំគ្រងឱ្យបានគង់វង្ស អស់កាលយូរអង្វែងតរៀងទៅ ។



www.elibraryofcambodia.org

# DEDICATION

We, the artists involved in this publication would like to dedicate this book to the great masters from all generations, who are committed to the creation of masterpieces for the younger generation.

We also would like to dedicate this publication to Master Pol Sam Oeun, who died during the Pol Pot Regime and who had created folk dances, especially this pestle dance. We send our prayers and wishes to him.

We hope that this small book will be useful to the young Cambodian researchers who are dedicated to protecting and preserving their heritage.



www.elibraryofcambodia.org

# អារម្ភកថា

វាសនាអនាគតសង្គមខ្មែរ អាស្រ័យទាំងស្រុងលើការសាបព្រួស បណ្ដុះបណ្ដាលធនធានមនុស្ស នាពេលបច្ចុប្បន្ន។ ខេមរជនគ្រប់រូបត្រូវមានភារកិច្ចជួយថែរក្សាសម្បត្តិវប្បធមជាតិ គឺត្រូវពង្រឹងជំហរ របស់ខ្លួនពឹងលើគំនិតផ្ទង់ផ្ចិត ឱ្យដល់កម្រិត នៃការឆ្លាតវាងវៃ ធ្វើឱ្យសមហេតុមិនត្រូវអណ្តែតត្រសែត តាមកម្មវាសនានោះឡើយ ព្រោះវប្បធមិមានតម្លៃក្រៃអនេក ជាបង្អែកដូងព្រលឹងរបស់ជាតិ ។

បច្ចុប្បន្នកាលជាថ្នាលជីវិតថ្មី យុវជន យុវតី មិនត្រូវបណ្ដោយខ្លួនទៅតាមការត្រេកត្រអាលនៃ បរិយាកាសសង្គមឡើយ ត្រូវខំលើកតម្លៃធ្វើឬកពា ព្យាយាមដុសខាត់ចិត្តតាំងគំនិត ចេះពិចារណា ខំស្ដាប់នានូវវិជ្ជាជាកម្លាំង ក្រើនស្មារតីភ្ញាក់រឭកគិតធានាលើកកម្ពស់វប្បធមិជាតិ ។

កូនសៀវភៅរបាំប្រពៃណី ដែលអស់លោក លោកស្រី ប្រិយមិត្ត កំពុងអាននេះ គឺជាការព្យាយាម ជំនះរាល់ការលំបាក និងឧបសគ្គនានាដែលក្រុមស្រាវជ្រាវយើងខំកត់ត្រាចងក្រង សម្រិតសម្រាំង យ៉ាងលំអិត បញ្ជាក់ពីលក្ខណៈពិសេសរបស់របាំ ដោយទឹកចិត្តស្រលាញ់ និងដើម្បី រក្សាទុក និងបន្តឱ្យជំនាន់ក្រោយ ។ ក្នុងការកត់ត្រានេះ យើងជឿជាក់ថាប្រាកដជាមិនទាន់សុក្រឹត និងល្អប្រណីតនោះឡើយ ព្រោះបញ្ហាបច្ចេកទេស និងឯកសារគំរូមិនគ្រប់គ្រាន់ ។ ដូច្នេះសូមអស់លោក លោកស្រី មិត្តអ្នកស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ ដែលស្រលាញ់សិល្បៈជាតិមេត្តាជួយកែលំអបន្ថែមទៀត ជួយស្ដាប់នា យ៉ាងណាឱ្យការកត់ត្រានេះ ក្លាយជាឯកសារមានប្រយោជន៍ កុំមើលបំណាំ ដល់មាតុភូមិជាទីស្រលាញ់ របស់យើងគ្រប់ៗគ្នា ។



www.elibraryofcambodia.org

# PREFACE

The future of Khmer society will depend on the current development of human resources. Cambodian people need to strengthen their knowledge in order to preserve their cultural heritage. Creativity and initiative needs to be promoted for the betterment of our civil society.

Up to now, existing cultural documents are very limited and so therefore the artists of the National Theatre are trying their best to compile information about this folkloric dance, the Robam Angré (pestle dance) for the sake of its documentation repertoire.

This book will inform readers about the performance of this dance and all its different features. This publication will be very useful to the younger generation to use as a reference source and for research purposes.

However, the research team believes their work will still need to be improved upon and feels that it still needs more feedback. They therefore welcome and appreciate any critical comments that may help to make this book reach perfection.



www.elibraryofcambodia.org

# ប្រវត្តិរបាំគោះអង្រែ

របាំគោះអង្រែជារបាំរបស់ជនជាតិតួយ ជាជនជាតិដើមក្នុងអំបូរខ្មែរ-មន ដែលរស់នៅតាមភូមិភាគនៃជួរ ភ្នំដងរែក និងជើងភ្នំគូលែន ពោលគឺត្រង់ម្តុំជាំក្សាន្ត សំរោងចុងកាលបច្ចុប្បន្ន ។ ពីដើមគេឃើញមានការសម្តែងរបាំនេះ សឹងតែគ្រប់ស្រុកភូមិក្នុងកម្ពុជរដ្ឋសម្រាប់កំសាន្តសប្បាយ និងសម្តែងពីទឹកចិត្តរាប់អានស្និទ្ធស្នាលស្វាហាប់របស់ អ្នកស្រុកស្រែចំការ ។ គេនាំគ្នារាំលេងក្នុងពិធីបុណ្យទានឬពិធីអ្វីមួយ ដែលជាលក្ខណៈបុណ្យប្រពៃណីរបស់ខ្លួន ។

របាំនេះកើតឡើងពី ទំនៀមទម្លាប់របស់អ្នកស្រុកក្នុងការកែច្នៃអង្ករ ចិញ្ចឹមជីវិតដោយស្តែងចេញពីចង្វាក់ពលកម្មដ៏ សស្រាក់សស្រាំ ។ ពួកគេនាំគ្នាបង្កើតរបាំនេះឡើង គឺសម្រាប់សម្តែងនៅពេលសម្រាកពីការងាររបស់ពួកគេ ដើម្បីបន្ថយនូវបរិយាកាសនឿយហត់ ។ របាំនេះគេនិយមសម្តែងបំផុតក្នុងពិធីបុណ្យចូលឆ្នាំ និង ក្នុងរដូវច្រូតកាត់ស្រូវ ដូចជាបុណ្យដាលានជាដើម ។

អំឡុងឆ្នាំ ១៩៥៧ ដល់ឆ្នាំ ១៩៦៥ របាំនេះត្រូវបានគ្រូសាលាល្ខោនជាតិ កែច្នៃបន្ថែមដើម្បីពង្រូវក្នុងកម្មវិធីសិក្សា ។ ក្រុមស្រាវជ្រាវ ផ្នែករបាំប្រពៃណី នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក៏បានកែលំអជាបន្តបន្ទាប់រហូតមាន រូបភាពដូចបច្ចុប្បន្ននេះ ។

វង់ភ្លេងមហោរី ត្រូវបានជ្រើសរើស យកមកគំដរជូនរបាំគោះអង្រែ ។



www.elibraryofcambodia.org

# ឧបករណ៍ភ្លេង

Musical instrument

រនាតឯក RONEAT EK

រនាតធុង RONEAT THUNG

ខ្លុយ KLUY

តាខេ TAKHE

ទ្រអ៊ូរ TRO-OU

ទ្រសោតូច TRO-SO-TOCH

ស្គរដៃ SKOR-DEI

ស្គររមនា SKOR-ROMANEA

ឈឹង CHHOEUNG





www.elibraryofcambodia.org





www.elibraryofcambodia.org

# សំលៀកបំពាក់បុរសនារីក្លូងរបាំគោះអង្រែ

**នារី** អ្នករាំ Solo ៣នាក់ ស្លៀក

១-សំពត់លយឆាយភ្លីខាងមុខ

២-អាវរំភើយ ឆែឃុាំ

៣-ពាក់ឈៀងកន្សែងទំលាក់ចុងទាំងពីរមកក្រោមរួចកាច់ជាផ្កាក្រោមចង្កេះខាងស្តាំបន្តិច ។

**នារី** អ្នករាំធម្មតា ៣នាក់ ស្លៀក

១-សំពត់ចងក្បិន

២-អាវណេយ

៣-រុំកន្សែងព័ទ្ធជងខ្លួនចងពង់កាច់ផ្កាលើដើមទ្រូងខាងឆ្វេងគ្មានកន្ទុយជាយ គឺចងក្បិនពីលើ

**បុរស** អ្នករាំ Solo និងអ្នករាំធម្មតាសំលៀកបំពាក់ដូចគ្នា ប៉ុន្តែខុសតែពណ៌ទេ

១-អាវសន្ទះ

២-ខោចែវពាក់កណ្តាលស្មងជើង

៣-កន្សែងចងចង្កេះ

៤-មួកស្លឹកត្នោត សម្រាប់អ្នករាំបុរស

**បុរស** គោះអង្រែ ៦នាក់ គឺសំលៀកបំពាក់ដូចអ្នករាំដែរ ប៉ុន្តែខុសតែពណ៌ និងគ្មានមួក ។

**អ្នកចំរៀង** មានសំលៀកបំពាក់

១-អាវសន្ទះ

២-ខោចែវជើងវែង

៣-ក្រមាបង់ក ចំណែកពណ៌ខុសគេ ចំណែកពណ៌អ្នករាំនិងអ្នកគោះអង្រែ អាស្រ័យទៅលើយើងជាអ្នករើសឱ្យវាស៊ីគ្នា និងមានលក្ខណៈពណ៌សម្បុរជាតិខ្មែរតែប៉ុណ្ណោះ ។



www.elibraryofcambodia.org





**ចំណុចសំខាន់ក្នុងរបាំគោះអង្រែ**

គេរាំជំទើតកែងជើង គឺ ប្រើចុងប្រអប់ជើង

តាំងពីចាប់ផ្ដើមរាំរហូតដល់ចប់





www.elibraryofcambodia.org



៣







www.elibraryofcambodia.org








www.elibraryofcambodia.org








www.elibraryofcambodia.org









www.elibraryofcambodia.org


១
២
៣

# វគ្គ និង ក្បាច់របាំ

របាំគោះអង្រែ មានអ្នកគោះអង្រែប្រាំមួយនាក់ អ្នកកំប្លែងម្នាក់ អ្នករាំប្រុសប្រាំមួយនាក់ ស្រីប្រាំមួយនាក់ សរុបទាំងអស់ ១៩ នាក់ ។

របាំគោះអង្រែរាំ សរុបមានចំនួន ២៨៨ ចង្វាក់ ប៉ុន្តែនៅក្នុងចង្វាក់នោះគេរាំដដែលៗ វគ្គទី១មាន ៤៨ចង្វាក់ វគ្គទី២មាន ៤៨ចង្វាក់ គូទីមួយរាំ ៩៦ចង្វាក់ គូទីពីររាំ ៩៦ចង្វាក់ គូទីពីររាំថែមជាមួយគូទី១ ៤៨ចង្វាក់ទៀតគូទី២ចេញ តែគូទីមួយរាំថែមទាំង ៤៨ចង្វាក់ solo សរុបទាំងអស់ ២៨៨ ចង្វាក់ គូទីពី ១៤៤ចង្វាក់។ (ពេលរាំចង្វាក់ជើងនិងដៃម្តងៗមានបីចង្វាក់) ឯចង្វាក់ទី៤ គឺជាចលនាខ្យល់នៃកូនចង្វាក់ជើង ។

**ក្បាច់វគ្គទី I** : លោតក្នុងអង្រែមុន និង ក្រៅអង្រែក្រោយ ។

ក្បាច់វគ្គទី១នេះគឺលោតចូលក្នុងអង្រែ បានតែពីរចង្វាក់ និងលោតក្រៅអង្រែ មួយចង្វាក់ និងក្បាច់ខ្លះទៀតលោតក្រៅ៣ចង្វាក់ សរុបគឺ ៣ចង្វាក់ ចាប់ផ្តើមរាប់ពីចង្វាក់ទី១ ទី២ ទី៣ រហូតដល់ ៤៨ចង្វាក់ ។

**ក្បាច់វគ្គទី II** : លោតក្រៅអង្រែមុខ និង ក្នុងអង្រែក្រោយ ។

ក្បាច់វគ្គទី២នេះគឺលោតក្រៅអង្រែពីរចង្វាក់ និងក្នុងអង្រែមួយចង្វាក់ សរុបគឺ ៣ចង្វាក់ ចាប់ផ្តើមរាប់ពី ចង្វាក់ទី១ ទី២ ទី៣ រហូតដល់៤៨ចង្វាក់ និងក្បាច់ខ្លះទៀតលោតក្រៅអង្រែ៣ចង្វាក់។



www.elibraryofcambodia.org

# វគ្គទី ១

គូទី១ មានអ្នករាំ ៣គូ គឺរាំទាំងក្បាច់វគ្គទី១ និងក្បាច់វគ្គទី២មាន ៥៦ចង្វាក់
គូទី១ចប់ ចេញ គូទី២ចូល



# វគ្គទី ២



គូទី២ មានអ្នករាំ ៣គូ គឺរាំទាំងក្បាច់វគ្គទី១ និងក្បាច់វគ្គទី២មាន ៥៦ចង្វាក់ ។ ចប់ចូលវគ្គថ្មី ។



www.elibraryofcambodia.org

# វគ្គទី ៣

គូទី២និងគូទី១រាំទាំងអស់គ្នា ក្នុងអង្រែទីមួយៗអ្នករាំមានពីរគូ សរុប៦គូ រាំតែក្បាច់វគ្គទី១ទេ គឺមាន ៤៨ចង្វាក់ ( ចប់ )គូទី២ចេញ គូទី១នៅរាំ សូឡូ( Solo )



# វគ្គទី ៤



គូទី១ គឺរាំក្បាច់វគ្គទី២មាន ៤៨ចង្វាក់ សូឡូញាប់ ( ចប់ )



www.elibraryofcambodia.org







## ចម្រៀងបនផ្ទៃស្រុកខ្មែរ

I. ឱផ្ទៃស្រុកខ្មែរៗ យប់ខែភ្លឺថ្លា អ្នកស្រុកធ្វើការ ឱណាលោកអើយ
អ្នកស្រុកធ្វើការ អើៗៗ ធ្វើកាគ្រប់ដៃ ។

II. មានជាងឈូសឈើៗ រៀនធ្វើផ្ទះថ្មី រីពូកស្រីៗ ឱណាលោកអើយ
រីពូកស្រីៗ អើៗៗ អុំស្នែអង្ករ ។

III. មានជាងចម្លាក់ៗ មានអ្នកគូរស្គរ កញ្ញារូបល្អ ឱណាលោកអើយ
កញ្ញារូបល្អ អើៗៗ ផ្សៀងករវាត់ខ្នារ ។



www.elibraryofcambodia.org







## បទសង្សារស្រុកខ្មែរ

(មុនផ្ទុកចេញ ... ឮសម្លេងពីក្នុង)

I. យុវជនកម្ពុជា រួចផុតវេទនា បានមកជួបជុំ
ជីវភាពសុខដុម ភារៈដ៏ធំ ដីស្រែមិនភ្លេច ។

II. បោកបែនប្រមូល ផលស្រូវដាក់ចូល ជង្រុករួចស្រេច
ឥឡូវថ្ងៃលិច ក្រោមខែភ្លឺផ្លេក រាំលេងកំសាន្ត ។

(ផ្ទុកច្រៀងដើរចេញពីក្នុង)

III. ឱណាឥឡូវថ្ងៃលិច ក្រោមខែភ្លឺផ្លេក រាំលេងកំសាន្ត អឺយ ។



www.elibraryofcambodia.org



## ចម្រៀងបងរមាំអង្រែ (title uncertain)

I. ថ្ងៃនេះយើងខ្ញុំ អើ-អឺ អឺង អើយ ក្រុមកសិករ (Bis)

មានចិត្ត រីករាយសាទរ អើអឺ អឺងអើយ ច្រៀងរាំអង្រែ (Bis)

**១. ជើង :** ជើងទាំងពីរឈរទន្ទឹមគ្នា រួចបន្ទន់ជង្គង់បន្តិច ( ពេលឱនសំពះភ្ញៀវ )

**២. ដងខ្លួននិងចង្កេះ :** ដងខ្លួននិងចង្កេះត្រង់ ឱនបន្តិច ( ពេលគោរពភ្ញៀវ )

**៣. ដៃ :** ដៃទាំងពីរសំពះភ្ញៀវស្មើទ្រូង កែងដៃទម្លាក់ស្របនឹងដងខ្លួន

**៤. ក្បាលនិងភ្នែក :** ក្បាលនិងភ្នែកត្រង់ សំឡឹងមើលទៅភ្ញៀវស្របនឹងក្បាល

**៥. មនោសញ្ចេតនា :** ញញឹមគោរពដោយសុភាពរាបសារ

*បញ្ជាក់ :* អ្នកពោះអង្រែទាំង៦នាក់ ឈរដោយយកអង្រែទល់នឹងចង្កេះ ជើងម្ខាងទប់កំពោល់រួចសំពះរួមគ្នាជាមួយនឹងអ្នករាំ គឺធ្វើចលនាទះដៃទៅចំហៀងខាងឆ្វេង និង ស្តាំ ។



www.elibraryofcambodia.org



ចង្វាក់ទី១

**១. ជើង :** អ្នកនៅចំហៀងខាងឆ្វេង ត្រូវបោះជើងស្តាំមកមុខដោយបន្ទន់បន្តិច អ្នកនៅចំហៀងខាងស្តាំ អូសជើងឆ្វេងមកដាក់ពីមុខជើងស្តាំ ដោយជំទើតកែងជើង ចំពាក់កណ្តាលកែងចាប់ពីប្រុសសួឡកណ្តាល ម្ខាងទៀតត្រឹមស្រីសួឡកណ្តាល ។

**២. ដងខ្លួននិងចង្កេះ :** ចង្វាក់ទី១និងទី២ត្រង់ ចង្វាក់ទី៣ ម្ខាងផ្អៀងស្តាំ ម្ខាងទៀតផ្អៀងឆ្វេង

**៣. ដៃ :** -ចង្វាក់ទី១ : ដៃទាំងពីរទះស្មើទ្រូង

-ចង្វាក់ទី២ : ដៃទះលើទ្រូងបន្តិច

-ចង្វាក់ទី៣ : ដៃទាំងពីរទះស្មើចុងចិញ្ចើម ។

**៤. ក្បាលនិងភ្នែក :** -ចង្វាក់ទី១ និង២ : ត្រង់

-ចង្វាក់ទី៣ : ផ្អៀងទៅឆ្វេង អ្នកនៅខាងស្តាំផ្អៀងទៅស្តាំ (សំឡឹងភ្ញៀវ) ។

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ

*បញ្ជាក់ :*ម្តងផ្អៀងឆ្វេង ម្តងផ្អៀងស្តាំទះដៃបញ្ច្រាសគ្នារហូតដល់ចប់ចម្រៀងថា (មានចិត្តរីករាយសាទរ Bis) ដើររាំចេញ អ្នករាំគូរទី១នាំមុខ ចំណែកដៃទាំងពីរទះតាមចង្វាក់ រហូតដើរមកដល់កន្លែងរាំ។



www.elibraryofcambodia.org

# ក្បាច់វគ្គទី១

ចង្វាក់ទី១ រាំទល់មុខគ្នា ស្រីលោតទៅស្ដាំ ស្រីលោតមកស្ដាំ

**១. ជើង** : -ចង្វាក់ទី១ : ជើងស្ដាំលោតចូលក្នុងអង្រែស្ដាំ ក្រោមឆ្វេងលើកជំទើត (ខាងក្នុងអង្រែ)

-ចង្វាក់ទី២ : ជើងឆ្វេងក្រោម ស្ដាំលើកជំទើត (ខាងក្នុងអង្រែ)

-ចង្វាក់ទី៣ : ជើងស្ដាំក្រោម ឆ្វេងលើកពាក់កណ្ដាលស្មងជើង (ក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ** : ចង្វាក់ទី១ ទី២ត្រង់ ចង្វាក់ទី៣ ផ្ទៀងស្ដាំងាកឆ្វេង។

**៣. ដៃ** : -ចង្វាក់ទី១ : ដៃឆ្វេងលា រង់ក្រោមចុងដង្ហើម ដៃស្ដាំជីពក្រោមចុងដង្ហើម

-ចង្វាក់ទី២ : លាវង់បន្តិចលើទ្រូង

-ចង្វាក់ទី៣ : ដៃស្ដាំលើកត្រឹមចុងចិញ្ចើម ស្រីដៃឆ្វេងជីពទាញអស់មកក្រោយ

**៤. ក្បាលនិងភ្នែក** : - ចង្វាក់ទី១និងទី២ : ត្រង់

- ចង្វាក់ទី៣ : ផ្ទៀងស្ដាំងាកឆ្វេង ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ

*បញ្ជាក់ :* ប្រើទង្វន់លោតទៅចុងប្រអប់ជើង គឺមានកូនចង្វាក់តូចៗ នៅក្បាលជង្គង់ គឺជំទើតកែង



www.elibraryofcambodia.org



ចង្វាក់ទី១



ចង្វាក់ទី២



ចង្វាក់ទី៣



www.elibraryofcambodia.org

**ចង្វាក់ទី៩ : រាំទល់មុខគ្នា ស្រីលោតទៅឆ្វេង ប្រុសលោតទៅឆ្វេង**

**១. ជើង :** - ចង្វាក់ទី៤ : ជើងឆ្វេងលោតចូលក្នុងអង្រែ ឆ្វេងក្រោម ស្តាំលើកជំទើត (ខាងក្នុងអង្រែ)

- ចង្វាក់ទី៥ : ស្តាំក្រោម ឆ្វេងលើកជំទើត (ខាងក្នុងអង្រែ)

- ចង្វាក់ទី៦ : ឆ្វេងក្រោមស្តាំ លើកពាក់កណ្តាលស្មងជើង (ខាងក្រៅអង្រែ) ។

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៤និងទី៥ : ត្រង់

- ចង្វាក់ទី៦ : ផ្ទៀងឆ្វេងងាកស្តាំ

**៣. ដៃ :** - ចង្វាក់ទី៤ : ដៃទាំងពីរជីពទន្ទឹមគ្នាក្រោមចុងដង្ហើម

- ចង្វាក់ទី៥ : ដៃទាំងពីរជីពមូលចូលគ្នាឡើងបញ្ចិតឆ្វេងបន្តិចស្មើទ្រូង

- ចង្វាក់ទី៦ : ម្រាមដៃទាំងពីរ លោតទះផ្ចិបគ្នាចំហៀងឆ្វេងត្រឹមចុងចិញ្ចើម

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៤និងទី៥ : ក្បាលត្រង់

- ចង្វាក់ទី៦ : ក្បាលផ្ទៀងឆ្វេងងាកស្តាំ ភ្នែកសំឡឹងគូរាំជាមួយគ្នា

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤



ចង្វាក់ទី៥



ចង្វាក់ទី៦



www.elibraryofcambodia.org

**ចង្វាក់ទី៧ : រាំលោតក្រោមវង្វៀត្រឡប់ខ្លួនកន្លះជុំ ពីឆ្វេងមកស្តាំ ទល់មុខគ្នា នៅខាងឆ្វេងមេក្បាច់**

**១. ជើង :** -ចង្វាក់ទី៧ : បោះជើងស្តាំមុខ ជើងឆ្វេងក្រោយ ជំទើតកែងទាំងពីរ ទម្ងន់ដងខ្លួនស្មើគ្នា

-ចង្វាក់ទី៨ : ជើងស្តាំវិលកន្លះជុំ ជើងឆ្វេងដកជំទើតស្មើគ្នាពេលបង្វិលខ្លួន

-ចង្វាក់ទី៩ : ស្តាំក្រោម ឆ្វេងលើកពាក់កណ្តាលស្មងជើង

**២. ដងខ្លួននិងចង្កេះ :** -ចង្វាក់ទី៧ : ផ្អៀងស្តាំបង្វិលត្រឡប់ខ្លួនកន្លះជុំពីឆ្វេងមកស្តាំ

-ចង្វាក់ទី៨ : ត្រង់

-ចង្វាក់ទី៩ : ផ្អៀងឆ្វេង

**៣. ដៃ :** -ចង្វាក់ទី៧ : ដៃឆ្វេងវង់ត្រឹមចុងចិញ្ចើម ដៃស្តាំក្រោមស្មើចង្កេះលូកទះដៃគ្នាជាមួយគូរាំ

-ចង្វាក់ទី៨ : ដៃទាំងពីរទះទប់គ្នាស្មើទ្រូង

-ចង្វាក់ទី៩ : ដៃស្តាវង់មកលើត្រឹមចុងចិញ្ចើម

**៤. ក្បាលនិងភ្នែក :** -ចង្វាក់ទី៧ : ផ្អៀងស្តាំ

-ចង្វាក់ទី៨ : ត្រង់ វិលមកផ្អៀងឆ្វេង

-ចង្វាក់ទី៩ : ផ្អៀងឆ្វេង ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ។



www.elibraryofcambodia.org



ចង្វាក់ទី៧



ចង្វាក់ទី៨



ចង្វាក់ទី៩



www.elibraryofcambodia.org

## ចង្វាក់ទី ១០ : រាំទល់មុខគ្នា ស្រីទៅឆ្វេងមែប្រុស ប្រុសលោតមកឆ្វេងមែស្រី

**១. ជើង :** -ចង្វាក់ទី១០ : ជើងឆ្វេងលោតចូលទៅក្នុងអង្រែឆ្វេងក្រោម ស្តាំលើកជិតទើតពកែង ( ក្នុងអង្រែ)

-ចង្វាក់ទី១១ : ស្តាំក្រោម ឆ្វេងលើកជិតទើត ( ក្នុងអង្រែ)

-ចង្វាក់ទី១២ : ឆ្វេងក្រោម ស្តាំលើកពាក់កណ្តាលស្មងជើង ( ខាងក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** -ចង្វាក់ទី១០និងទី១១ : ដងខ្លួននិងចង្កេះត្រង់

-ចង្វាក់ទី១២ : ផ្សៀងឆ្វេងងាកស្តាំ

**៣. ដៃ :** -ចង្វាក់ទី១០ : ដៃទាំងពីរទះត្រគាក

-ចង្វាក់ទី១១ : ដៃទាំងពីរទះខាងក្រោយក្រោមឆ្អឹងក្បាល

-ចង្វាក់ទី១២ : ដៃទាំងពីរទាញមកឆ្វេងទះត្រឹមចុងចិញ្ចើម

**៤. ក្បាលនិងភ្នែក :** -ចង្វាក់ទី១០និងទី១១ : ក្បាលនិងភ្នែកត្រង់

-ចង្វាក់ទី១២ : ផ្សៀងឆ្វេងងាកស្តាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១០



ចង្វាក់ទី១១



ចង្វាក់ទី១២



www.elibraryofcambodia.org

## ចង្វាក់ទី ១៣ : រាំទល់មុខគ្នា ស្រីលោតចកស្ដាំដៃ ប្រុសលោតទៅស្ដាំដៃវិញ

**១. ជើង** -ចង្វាក់ទី១៣ : ជើងស្ដាំលោតចូលក្នុងអង្រែស្ដាំក្រោម ឆ្វេងលើកជំទើត (ខាងក្នុងអង្រែ)

-ចង្វាក់ទី១៤ : ឆ្វេងក្រោម ស្ដាំលើកជំទើត (ខាងក្នុងអង្រែ)

-ចង្វាក់ទី១៥ : ស្ដាំក្រោម ឆ្វេងលើកពាក់កណ្ដាលស្មងជើង (ខាងក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** -ចង្វាក់ទី១៣និងទី១៤ : ដងខ្លួននិងចង្កេះត្រង់

-ចង្វាក់ទី១៥ : ផ្អៀងស្ដាំងាកឆ្វេង

**៣. ដៃ :** ដៃទាំងពីរទម្លាក់មកមុខក្រោមថ្លេង (ស្ដាំនិងឆ្វេង)

-ចង្វាក់ទី១៣ : ដៃស្ដាំប្រុស និង ដៃស្ដាំស្រីទះជាមួយគ្នា

-ចង្វាក់ទី១៤ : ដៃឆ្វេងប្រុស និង ដៃឆ្វេងស្រីទះជាមួយគ្នា

-ចង្វាក់ទី១៥ : ដៃទាំងពីរលើកជីពមូល ទះគ្នាស្មើចុងចិញ្ចើម មកចំហៀងស្ដាំ

**៤. ក្បាលនិងភ្នែក :** -ចង្វាក់ទី១៣និងទី១៤ : ត្រង់

-ចង្វាក់ទី១៥ : ផ្អៀងស្ដាំងាកឆ្វេង ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១៣



ចង្វាក់ទី១៤



ចង្វាក់ទី១៥



www.elibraryofcambodia.org

**ចង្វាក់ទី ១៦ : រាំលោតក្រៅអង្រែត្រឡប់ខ្លួនកន្លះជុំពីស្តាំទៅឆ្វេងទល់មុខគ្នា ទៅស្តាំថៃខ្លាចង**

**១. ជើង :** - ចង្វាក់ទី១៦ : បោះជើងឆ្វេងមុខ ជើងស្តាំក្រោយ ជំទើតទាំងពីរ ទម្ងន់ដងខ្លួនស្មើគ្នា

- ចង្វាក់ទី១៧ : ជើងឆ្វេងវិលកន្លះជុំ ជើងស្តាំដកជំទើតស្មើគ្នាពេលវិលហើយ

- ចង្វាក់ទី១៨ : ដកជើងឆ្វេងមកក្រោយ ទប់ទម្ងន់ ស្តាំលើកពាក់កណ្តាលស្មងជើង (ក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី១៦ : ផ្ទៀងស្តាំ

- ចង្វាក់ទី ១៧ : ដងខ្លួននិងចង្កេះត្រង់ ត្រឡប់ខ្លួនកន្លះជុំពីស្តាំទៅឆ្វេង

- ចង្វាក់ទី១៨ : ផ្ទៀងស្តាំ

**៣. ដៃ :** - ចង្វាក់ទី១៦ : ដៃស្តាំលើកវង់ត្រឹមចិញ្ចើម ដៃឆ្វេងក្រោមស្មើចង្កេះ លូកដៃទះគ្នាជាមួយគូរាំ

- ចង្វាក់ទី១៧ : ដៃទាំងពីរទះជាមួយគ្នាស្មើទ្រូង វិលស្របដងខ្លួន

- ចង្វាក់ទី១៨ : ដៃឆ្វេងវង់ត្រឹមចុងចិញ្ចើម ដៃស្តាំនៅក្រោមស្មើ និងចង្កេះលូកដៃទះគ្នាជាមួយគូរាំ

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី១៦ : ផ្ទៀងឆ្វេង

- ចង្វាក់ទី១៧ : វិលមកផ្ទៀងស្តាំ

- ចង្វាក់ទី១៨ : ផ្ទៀងស្តាំ ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១៦



ចង្វាក់ទី១៧



ចង្វាក់ទី១៨



www.elibraryofcambodia.org

## ចង្វាក់ទី ១៩ : រាំទល់មុខគ្នា ស្រីលោតទៅស្តាំ ប្រុសលោតចកស្តាំ

**១. ជើង :** - ចង្វាក់ទី១៩ : ជើងស្តាំលោតចូលក្នុងអង្រែស្តាំក្រោម ឆ្វេងលើកជំទើត ( ខាងក្នុងអង្រែ)

- ចង្វាក់ទី២០ : ឆ្វេងក្រោម ស្តាំលើកជំទើត ( ខាងក្នុងអង្រែ)

- ចង្វាក់ទី២១ : ស្តាំក្រោម ឆ្វេងលើកពាក់កណ្តាលស្មងជើង ( ខាងក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី១៩និងទី២០ : ដងខ្លួននិងចង្កេះត្រង់

- ចង្វាក់ទី២១ : ផ្អៀងស្តាំងាកឆ្វេង

**៣. ដៃ :** - ចង្វាក់ទី១៩និងទី២០ : ដៃឆ្វេងលាវង់ ដៃស្តាំជីពក្រោមថ្ពូង ( ស្រីនិងប្រុស)

- ចង្វាក់ទី២០ : លាវង់បន្តិច

- ចង្វាក់ទី២១ : ដៃស្តាំលើកស្មើចុងចិញ្ចើម ដៃឆ្វេងក្រោមជីពទាញមកក្រោយអស់ដៃ

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី១៩និង២០ : ត្រង់

- ចង្វាក់ទី២១ : ផ្អៀងស្តាំងាកឆ្វេង ភ្នែកសំឡឹងតួរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១៩



ចង្វាក់ទី២០



ចង្វាក់ទី២១



www.elibraryofcambodia.org

## ចង្វាក់ទី ២២ : រាំចល់មុខផ្កាស្រីលោតមកឆ្វេង ប្រុសលោតទៅឆ្វេងវិញ

**១. ជើង :** - ចង្វាក់ទី២២ : ជើងឆ្វេងលោតចូលក្នុងអង្រែ ស្តាំលើក ( ខាងក្នុងអង្រែ)

- ចង្វាក់ទី២៣ : ស្តាំក្រោម ឆ្វេងលើកជំទើត ( ក្នុងអង្រែ)

- ចង្វាក់ទី២៣ : ឆ្វេងក្រោម ស្តាំលើកពាក់កណ្តាលស្មងជើង ( ខាងក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី២២និង២៣ : ត្រង់

- ចង្វាក់ទី២៤ : ផ្សៀងឆ្វេងងាកស្តាំ

**៣. ដៃ :** - ចង្វាក់ទី២២ : ដៃស្តាំវង់ ដៃឆ្វេងជីព

- ចង្វាក់ទី២៣ : លាវង់បន្តិច

- ចង្វាក់ទី២៤ : ដៃឆ្វេងវង់ត្រឹមចុងចិញ្ចើម ដៃស្តាំជីពទាញមកក្រោយអស់ដៃ

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី២២និង២៣ : ក្បាលនិងភ្នែកត្រង់

- ចង្វាក់ទី២៤ : ផ្សៀងឆ្វេងងាកស្តាំ ភ្នែកសំឡឹងតួរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី២២



ចង្វាក់ទី២៣



ចង្វាក់ទី២៤



www.elibraryofcambodia.org

## ចង្វាក់ទី ២៥ : រាំទល់មុខគ្នាស្រីលោតទៅស្តាំ ប្រុសលោតមកស្តាំ

១. ជើង : - ចង្វាក់ទី២៥ : ជើងស្តាំលោតចូលក្នុងអង្រែ ជើងឆ្វេងលើក ( ខាងក្នុងអង្រែ)

- ចង្វាក់ទី២៦ : ឆ្វេងក្រោម ស្តាំលើកជំទើត ( ខាងក្នុងអង្រែ)

- ចង្វាក់ទី២៧ : ស្តាំក្រោម ឆ្វេងលើកពាក់កណ្តាលស្មងជើង ( ខាងក្រៅអង្រែ)

២. ដងខ្លួននិងចង្កេះ : - ចង្វាក់ទី២៥និង២៦ : ត្រង់

- ចង្វាក់ទី២៧ : ផ្អៀងស្តាំងាកឆ្វេង

៣. ដៃ : - ចង្វាក់ទី២៥ : ដៃឆ្វេងវង់ ដៃស្តាំជីពក្រោមត្រឹមចុងដង្ហើម

- ចង្វាក់ទី២៦ : លាវង់បន្តិច

- ចង្វាក់ទី២៧ : ដៃស្តាំវង់ត្រឹមចុងចិញ្ចើម ដៃឆ្វេងក្រោមជីពទាញមកក្រោយអស់ដៃ

៤. ក្បាលនិងភ្នែក : - ចង្វាក់ទី២៥និង២៦ : ត្រង់

- ចង្វាក់ទី២៧ : ផ្អៀងស្តាំងាកឆ្វេង ភ្នែកសំឡឹងចូរាំ

៥. មនោសញ្ចេតនា : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី២៥



ចង្វាក់ទី២៦



ចង្វាក់ទី២៧



www.elibraryofcambodia.org

## ចង្វាក់ទី ២៨ : រាំទល់មុខគ្នា ស្រីលោតមកឆ្វេង ប្រុសលោតទៅឆ្វេង

១. **ជើង** : - ចង្វាក់ទី២៨ : ជើងឆ្វេងលោតចូលក្នុងអង្រែឆ្វេងក្រោម ស្ដាំលើកជំទើតកែង ( ខាងក្នុងអង្រែ)

- ចង្វាក់ទី២៩ : ស្ដាំក្រោម ឆ្វេងលើកជំទើតកែង ( ខាងក្នុងអង្រែ)

- ចង្វាក់ទី៣០ : ឆ្វេងក្រោម ស្ដាំលើកពាក់កណ្ដាលខ្នងជើង

២. **ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី២៨និង២៩ : ដងខ្លួននិងចង្កេះត្រង់

- ចង្វាក់ទី៣០ : ផ្ទៀងឆ្វេងងាកស្ដាំ

៣. **ដៃ** : - ចង្វាក់ទី២៨ : ដៃទាំងពីរជីពចូលគ្នាក្រោមចុងដង្ហើម

- ចង្វាក់ទី២៩ : ដៃទាំងពីរជីពចូលគ្នាឡើងបញ្ឆិតឆ្វេងបន្តិចស្មើទ្រូង

- ចង្វាក់ទី៣០ : ទះផ្ចិបគ្នាចំហៀងឆ្វេងត្រឹមចុងចិញ្ចើម

៤. **ក្បាល និង ភ្នែក** : - ចង្វាក់ទី២៨-២៩ : ត្រង់

- ចង្វាក់ទី៣០ : ផ្ទៀងឆ្វេង ងាកស្ដាំ ភ្នែកសំឡឹងគូរាំជាមួយគ្នា

៥. **មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី២៨



ចង្វាក់ទី២៩



ចង្វាក់ទី៣០



www.elibraryofcambodia.org

**ចង្វាក់ទី ៣១ : រាំលោតក្រោមអង្រែត្រឡប់ខ្លួនកន្លះជុំពីឆ្វេងមកស្តាំទល់មុខគ្នា នៅឆ្វេងមេឆ្លាង**

**១. ជើង** : - ចង្វាក់ទី៣១ : បោះជើងស្តាំមុខ ជើងឆ្វេងក្រោយ ជំទើតកែងទាំងពីរ (ទំងន់ស្មើគ្នា)

- ចង្វាក់ទី៣២ : ជើងស្តាំវិលកន្លះជុំ ជើងឆ្វេងដកជំទើតកែងស្មើគ្នាពេលវិលហើយ

- ចង្វាក់ទី៣៣ : ដកជើងស្តាំលោតមកក្រោយលើកជើងឆ្វេងពាក់កណ្តាលស្មងជើង

**២. ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី៣១ : ផ្ទៀងស្តាំ

- ចង្វាក់ទី៣២ : ត្រឡប់ខ្លួនកន្លះជុំពីឆ្វេងមកស្តាំ

- ចង្វាក់ទី៣៣ : ផ្ទៀងស្តាំ

**៣. ដៃ** : - ចង្វាក់ទី៣១ : ដៃឆ្វេងវង់ត្រឹមចុងចិញ្ចើម ដៃស្តាំស្មើចង្កេះលូកដៃទះគ្នាជាមួយគូរាំ

- ចង្វាក់ទី៣២ : ដៃទាំងពីរទះគ្នាស្មើទ្រូងវិលស្របដងខ្លួន

- ចង្វាក់ទី៣៣ : ដៃស្តាំជីពលាវង់ត្រឹមចុងចិញ្ចើមដៃឆ្វេងក្រោមស្មើចង្កេះលូកដៃ

ទះគ្នាជាមួយគូរាំ

**៤. ក្បាលនិងភ្នែក** : - ចង្វាក់ទី៣១ : ផ្ទៀងស្តាំ

- ចង្វាក់ទី៣២ : វិលមកផ្ទៀងឆ្វេង

- ចង្វាក់ទី៣៣ : ផ្ទៀងឆ្វេង ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៣១



ចង្វាក់ទី៣២



ចង្វាក់ទី៣៣



www.elibraryofcambodia.org

## ចង្វាក់ទី ៣៩ : រាំទល់មុខគ្នា ស្រីទៅឆ្វេងមែប្រុស ប្រុសលោតមកឆ្វេងមែស្រី

**១. ជើង :** - ចង្វាក់ទី៣៤ : ជើងឆ្វេងលោតចូលក្នុងអង្រែ ឆ្វេងក្រោមស្តាំលើកជំទើត (ខាងក្នុងអង្រែ)

- ចង្វាក់ទី៣៥ : ស្តាំក្រោម ឆ្វេងលើកជំទើត (ខាងក្នុងអង្រែ)

- ចង្វាក់ទី៣៦ : ឆ្វេងក្រោម ស្តាំលើកពាក់កណ្តាលស្មងជើង

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៣៤និង៣៥ : ដងខ្លួននិងចង្កេះត្រង់

- ចង្វាក់ទី៣៦ : ផ្ទៀងឆ្វេងងាកស្តាំ

**៣. ដៃ :** - ចង្វាក់ទី៣៤ : ដៃទាំងពីរទះត្រគាក

- ចង្វាក់ទី៣៥ : ដៃទាំពីរទះខាងក្រោយក្រោមឆ្អឹកក្បៀន

- ចង្វាក់ទី៣៦ : ដៃទាំងពីរទាញមកឆ្វេងទះត្រឹមចុងចិញ្ចើម

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៣៤និង៣៥ : ក្បាលនិងភ្នែកត្រង់

- ចង្វាក់ទី៣៦ : ផ្ទៀងឆ្វេងងាកស្តាំ ភ្នែកសំឡឹងគូររាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៣៤



ចង្វាក់ទី៣៥



ចង្វាក់ទី៣៦



www.elibraryofcambodia.org

**ចង្វាក់ទី ៣៧ : រាំទល់មុខគ្នា ស្រីលោតមកស្តាំដៃ ប្រុសលោតទៅស្តាំដៃ**

**១. ជើង :** - ចង្វាក់ទី៣៧ : ជើងស្តាំលោតចូលក្នុងអង្រែ ឆ្វេងលើកជំទើត (ខាងក្នុងអង្រែ)

- ចង្វាក់ទី៣៨ : ឆ្វេងក្រោម ស្តាំលើកជំទើត (ខាងក្នុងអង្រែ)

- ចង្វាក់ទី៣៩ : ស្តាំក្រោម ឆ្វេងលើកពាក់កណ្តាលស្មងជើង

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៣៧និង៣៨ : ដងខ្លួននិងចង្កេះត្រង់

- ចង្វាក់ទី៣៩ : ផ្ទៀងស្តាំងាកឆ្វេង

**៣. ដៃ :** ដៃទាំងពីរទម្លាក់មកមុខក្រោមទ្រូង

-ចង្វាក់ទី៣៧ : ដៃស្តាំប្រុស និង ដៃស្តាំស្រីទះគ្នា

-ចង្វាក់ទី៣៨ : ដៃឆ្វេងស្រី និង ដៃឆ្វេងប្រុសទះគ្នា

-ចង្វាក់ទី៣៩ : ដៃទាំងពីរមូលកដៃជីពចេញត្រឹមចុងចិញ្ចើម លើកមកចំហៀងខាងស្តាំទះដៃគ្នា

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៣៧និង៣៨ : ក្បាលនិងភ្នែកត្រង់

- ចង្វាក់ទី៣៩ : ផ្ទៀងស្តាំងាកឆ្វេង ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៣៧



ចង្វាក់ទី៣៨



ចង្វាក់ទី៣៩



www.elibraryofcambodia.org

**ចង្វាក់ទី ៩០ : រាំលោតក្រៅអង្រៃត្រឡប់ខ្លួនកន្លះជុំពីស្តាំទៅឆ្វេងទល់មុខគ្នា ទៅស្តាំបែរខ្នងចូល**

**១. ជើង :** - ចង្វាក់ទី៤០ : បោះជើងឆ្វេងមុខ ជើងស្តាំនៅក្រោយជំទើតជើងទាំងពីរ ( ក្រៅអង្រៃ)

- ចង្វាក់ទី៤១ : ជើងឆ្វេងវិលកន្លះជុំ ជើងស្តាំដកជំទើតស្មើគ្នាពេលវិលហើយត្រូវដក ជើងឆ្វេងមកទប់ទំងន់ ( ក្រៅអង្រៃ)

- ចង្វាក់ទី៤២ : ឆ្វេងក្រោម ស្តាំលើកពាក់កណ្តាលស្មងជើង ( ក្រៅអង្រៃ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៤០ : ផ្ទៀងឆ្វេង

- ចង្វាក់ទី៤១ : ត្រង់ ត្រឡប់ខ្លួនកន្លះជុំពីស្តាំទៅឆ្វេង

- ចង្វាក់ទី៤២ : ផ្ទៀងស្តាំ

**៣. ដៃ :** - ចង្វាក់ទី៤០ : ស្តាំលាវង់ត្រឹមចុងចិញ្ចើម ដៃឆ្វេងក្រោមស្មើចង្កេះល្អក់ដៃទះគ្នាជាមួយគូរាំ

- ចង្វាក់ទី៤១ : ដៃទាំងពីរទះគ្នាស្មើទ្រូង

- ចង្វាក់ទី៤២ : ដៃឆ្វេងវង់ត្រឹមចុងចិញ្ចើមដៃស្តាំលាត្រឹមចង្កេះល្អក់ ដៃទះគ្នាជាមួយគូរាំ

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៤០ : ផ្ទៀងឆ្វេង

- ចង្វាក់ទី៤១ :ផ្ទៀងស្តាំ

- ចង្វាក់ទី៤២ : ផ្ទៀងស្តាំ ភ្នែកសំឡឹងគូរាំជាមួយ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤០



ចង្វាក់ទី៤១



ចង្វាក់ទី៤២



www.elibraryofcambodia.org

## ចង្វាក់ទី ៩៧ : រាំចល់មុខគ្នា ស្រីលោតទៅស្តាំ ប្រុសលោតចកស្តាំ

១. ជើង : - ចង្វាក់ទី៤៣ : ជើងស្តាំលោតចូលក្នុងអង្រែស្តាំក្រោម ឆ្វេងលើក (ក្នុងអង្រែ)

- ចង្វាក់ទី៤៤ : ឆ្វេងក្រោម ស្តាំលើកជំទើត (ក្នុងអង្រែ)

- ចង្វាក់ទី៤៥ : ស្តាំក្រោម ឆ្វេងលើកពាក់កណ្តាលស្មងជើង (ក្រៅអង្រែ)

២. ដងខ្លួននិងចង្កេះ : - ចង្វាក់ទី៤៣និង៤៤ : ដងខ្លួននិងចង្កេះត្រង់

- ចង្វាក់ទី៤៥ : ផ្អៀងស្តាំងាកឆ្វេង

៣. ដៃ : - ចង្វាក់ទី៤៣និង៤៤ : ដៃឆ្វេងវង់ ដៃស្តាំជីពត្រឹមចុងដង្ហើម

- ចង្វាក់ទី៤៤ : លាវង់បន្តិច

- ចង្វាក់ទី៤៥ : ដៃស្តាំវង់ត្រឹមចុងចិញ្ចើម ដៃឆ្វេងជីពទាញមកក្រោយអស់ដៃ

៤. ក្បាលនិងភ្នែក : - ចង្វាក់ទី៤៣និង៤៤ : ក្បាលនិងភ្នែកត្រង់

- ចង្វាក់ទី៤៥ : ផ្អៀងស្តាំងាកឆ្វេង ភ្នែកសំឡឹងគូរាំ

៥. មនោសញ្ចេតនា : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤៣



ចង្វាក់ទី៤៤



ចង្វាក់ទី៤៥



www.elibraryofcambodia.org



ចង្វាក់ទី៤៣



ចង្វាក់ទី៤៤



ចង្វាក់ទី៤៥



www.elibraryofcambodia.org

## ចង្វាក់ទី ១៦ : រាំចល់មុខគ្នា ស្រីលោតទៅឆ្វេង ប្រុសលោតមកឆ្វេងវិញ

**១. ជើង :** - ចង្វាក់ទី៤៦ : ជើងឆ្វេងលោតចូលក្នុងអង្រែឆ្វេងក្រោម ស្តាំលើក ( ក្នុងអង្រែ)

- ចង្វាក់ទ៤៧ : ស្តាំក្រោម ឆ្វេងលើកជំទើត ( ក្នុងអង្រែ)

- ចង្វាក់ទី៤៨ : ឆ្វេងក្រោម ស្តាំលើកពាក់កណ្តាលស្មងជើង ( ខាងក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៤៦និង៤៧ : ដងខ្លួននិងចង្កេះត្រង់

- ចង្វាក់ទី៤៨ : ផ្ទៀងឆ្វេងងាកស្តាំ

**៣. ដៃ :** - ចង្វាក់ទី៤៦ : ដៃស្តាំលាវង់ត្រឹមចុងដង្ហើម ដៃឆ្វេងជីពកោមទ្រូង

- ចង្វាក់ទី៤៧ : លាវង់បន្តិច

- ចង្វាក់ទី៤៨ : ដៃឆ្វេងត្រឹមចុងចិញ្ចើម ដៃស្តាំជីពទាញមកក្រោយអស់ដៃ

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៤៦និង៤៧ : ក្បាលនិងភ្នែកត្រង់

- ចង្វាក់ទី៤៨ : ផ្ទៀងឆ្វេងងាកស្តាំ ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤៦



ចង្វាក់ទី៤៧



ចង្វាក់ទី៤៨

**ចប់ក្បាច់វគ្គទីមួយ ៤៨ចង្វាក់**



www.elibraryofcambodia.org

# ក្បាច់ទី ២

**ចង្វាក់ ទី ១ : រាំលោតក្រៅអង្រែ២ចង្វាក់ ក្នុងអង្រែ១ចង្វាក់ ខាងស្តាំថៃ)**

**១. ជើង** : - ចង្វាក់ទី១ : ជើងស្តាំលោតក្រៅអង្រែ ស្តាំក្រោមឆ្វេងលើក ( ក្រៅ)

- ចង្វាក់ទី២ : ជើងឆ្វេងក្រោម ស្តាំលើកលើកជំទើត ( ក្រៅ)

- ចង្វាក់ទី៣ : ជើងស្តាំក្រោមនៅក្នុងអង្រែជើងឆ្វេងលើកពាក់កណ្តាលស្មងជើង ( ក្នុង)

**២. ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី១និង២ : ត្រង់

- ចង្វាក់ទី៣ : ផ្ទៀងឆ្វេងងាកស្តាំ

**៣. ដៃ** : - ចង្វាក់ទី១ : រាំទល់មុខគ្នា ដៃស្តាំជីពត្រឹមចុងដង្ហើមដៃឆ្វេងលាជារង្វង់ត្រឹមចុងដង្ហើម

- ចង្វាក់ទី២ : ដៃស្តាំជីពមូលលាវង់ឡើងលើចុងដង្ហើមដៃឆ្វេងក្រោមវង់ផ្កាប់មូលបំរុងជីព

- ចង្វាក់ទី៣ : ដៃស្តាំលាវង់ត្រឹមចុងចិញ្ចើមដៃឆ្វេងជីពវង់ក្រោមចុងដង្ហើម

**៤. ភ្លែកនិងក្បាល** : - ចង្វាក់ទី១និងទី២ : ត្រង់

- ចង្វាក់ទី៣ : ផ្ទៀងឆ្វេងងាកស្តាំភ្លែកសំឡឹងតូ

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១



ចង្វាក់ទី២



ចង្វាក់ទី៣



www.elibraryofcambodia.org

**ចង្វាក់ទី ៤ : រាំក្រោអង្រែលោតបង្វិលចុងជើងកន្លះជុំពីស្តាំមកឆ្វេង ទល់មុខគ្នា ៣ចង្វាក់**

**១. ជើង :** - ចង្វាក់ទី៤ : ជើងឆ្វេងមុខ ជើងស្តាំក្រោយជំទើត ទម្ងន់លើជើងមុខ (ក្រោអង្រែ)

- ចង្វាក់ទី៥ : ជើងឆ្វេងវិលកន្លះជុំ ជើងស្តាំដកជំទើតស្មើគ្នាពេលវិលហើយ (ក្រោអង្រែ)

- ចង្វាក់ទី៦ : លោតដកជើងឆ្វេងមកក្រោយទប់ទម្ងន់ ស្តាំលើកពាក់កណ្តាលស្មងជើង (ក្រោអង្រែ)

**២. ដងខ្លួននិងចង្កេះ :** -ចង្វាក់ទី៤និងទី៥ : ត្រង់

-ចង្វាក់ទី៦ : បង្វិលត្រឡប់ខ្លួនកន្លះជុំ ហើយផ្ទៀងស្តាំងាកស្តាំ

**៣. ដៃ :** - ចង្វាក់ទី៤ : ទម្លាក់ដៃស្តាំលាវង់ទន្ទឹមនឹងដៃឆ្វេងជីពក្រោមទ្រូងចុងដង្ហើម

- ចង្វាក់ទី៥ : ដៃឆ្វេងជីពអូសលាវង់ឡើងលើស្មើចុងដង្ហើម ដៃស្តាំមូលកដៃបំរុងជីពក្រោមចុងដង្ហើម

-ចង្វាក់ទី៦ : ដៃឆ្វេងលើលាវង់ត្រឹមចុងចិញ្ចើម ដៃស្តាំជីពក្រោមចុងដង្ហើម

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៤និងទី៥ : ត្រង់

- ចង្វាក់ទី៦ : ផ្ទៀងស្តាំងាកស្តាំ ភ្នែកសម្លឹងគូ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤



ចង្វាក់ទី៥



ចង្វាក់ទី៦



www.elibraryofcambodia.org

**ចង្វាក់ទី ៩ : រាំលោតក្រៅអង្រែស្រីបែរមុខចេញក្រៅ ប្រុសបែរ មុខចូលក្នុង**

**១. ជើង :** - ចង្វាក់ទី៧ : ជើងស្ដាំលោតក្រៅអង្រែស្ដាំក្រោមឆ្វេងលើកជំទើត ( ក្រៅអង្រែ)

- ចង្វាក់ទី៨ : ជើងឆ្វេងក្រោម ជើងស្ដាំលើកជុំទើតកែង ( ក្រៅអង្រែ)

- ចង្វាក់ទី៩ : ជើងស្ដាំក្រោម ជើងឆ្វេងលើកពាក់កណ្ដាលខ្នងជើងស្រីបែរទៅក្រៅប្រុសបែរមកក្នុង ( ក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៧និងទី៨ : ត្រង់

- ចង្វាក់ទី៩ : ផ្អៀងឆ្វេងងាកស្ដាំ

**៣. ដៃ :** - ចង្វាក់ទី៧ : ដៃទាំងពីរជីពត្រឹមចង្កេះ

- ចង្វាក់ទី៨ : ដៃទាំងពីរជីពមូលកដៃលាផ្កាបំរុងលាច្រត់ចង្កេះ

- ចង្វាក់ទី៩ : ដៃទាំងពីរច្រត់ក្រោមចង្កេះបន្ដិច

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៧និងទី៨ : ត្រង់

- ចង្វាក់ទី៩ : ផ្អៀងឆ្វេងងាកស្ដាំ ភ្នែកសម្លឹងគូរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៧



ចង្វាក់ទី៨



ចង្វាក់ទី៩



www.elibraryofcambodia.org

## ចង្វាក់ទី ១០ : រាំលោតត្រឡប់ក្រោយកន្ទះជុំទីស្តាំចកឆ្វេងទល់មុខស្តាំថៃភ្លាក្រៅអង្រៃ ២ចង្វាក់ហើយបែរ ខ្នងបោះជើង ក្នុងអង្រៃ ១ចង្វាក់ នៅស្តាំថៃភ្លា

១. **ជើង** : - ចង្វាក់ទី១០ : លោតបោះជើងឆ្វេងមកក្រោយក្រៅអង្រែឆ្វេងក្រោមស្តាំលើកជំទើត ( ក្រៅអង្រែ)

- ចង្វាក់ទី១១ : ស្តាំក្រោម ឆ្វេងលើកជំទើត ( ខាងក្រៅអង្រែ)

- ចង្វាក់ទី១២ : លោតជើងឆ្វេងបោះមកក្រោយក្នុងអង្រែបែរខ្នងដាក់ភ្លាបញ្ឈិតនៅស្តាំដៃភ្លា ជើងស្តាំលើកពាក់កណ្តាលស្មងជើង ( ក្នុងអង្រែ)

២. **ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី១០និងទី១១ : ត្រង់

- ចង្វាក់ទី១២ : ផ្ទៀងស្តាំងាកស្តាំ

៣. **ដៃ** : - ចង្វាក់ទី១០ : ដៃឆ្វេងជីព ដៃស្តាំលាវង់ក្រោមចុងដង្ហើម

- ចង្វាក់ទី១១ : ដៃឆ្វេងជីពមូលបំរុងលាត្រឹមចុងដង្ហើម ដៃស្តាំលាមូលបំរុងលូកទះក្រោមចុងដង្ហើម

- ចង្វាក់ទី១២ : ដៃឆ្វេងលាវង់ត្រឹមចុងចិញ្ចើម ដៃស្តាំលូកទះភ្លាត្រឹមចង្កេះជាមួយគូ

៤. **ក្បាលនិងភ្នែក** : - ចង្វាក់ទី១០និងទី១១ : ត្រង់

- ចង្វាក់ទី១២ : ផ្ទៀងស្តាំងាកស្តាំ ភ្នែកសំឡឹងគូ

៥. **មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១០



ចង្វាក់ទី១១



ចង្វាក់ទី១២



www.elibraryofcambodia.org

**ចង្វាក់ទី ១៣ : រាំលោតក្រៅរង្វង់ត្រឡប់ខ្លួនកន្លះជុំ រាំពីឆ្វេងមកស្តាំទល់មុខគ្នា ៣ចង្វាក់**

**១. ជើង** : - ចង្វាក់ទី១៣ : ជើងស្តាំមុខ ជើងឆ្វេងក្រោយជំទើតទាំងពីរ ទម្ងន់ជើងមុខ ( ក្រៅ)

- ចង្វាក់ទី១៤ : ជើងស្តាំវិលកន្លះជុំ ជើងឆ្វេងដកជំទើតស្មើគ្នាពេលវិលហើយ ( ក្រៅ)

- ចង្វាក់ទី១៥ : ដកជើងស្តាំមកក្រោមទប់ទម្ងន់ ជើងឆ្វេងលើកពាក់កណ្តាលស្មងជើង ( ក្រៅ)

**២. ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី១៣ និង ១៤ : ផ្ទៀងស្តាំ

- ចង្វាក់ទី១៥ : ផ្ទៀងឆ្វេង

**២. ដៃ** : - ចង្វាក់ទី១៣ : ទម្លាក់ដៃស្តាំត្រឹមចង្កេះចាប់ដៃគ្នាជាមួយគូរាំ ដៃឆ្វេងលាវង់ត្រឹមចុងចញ្ចើម

- ចង្វាក់ទី១៤ : ដៃចាប់ជាមួយគូរាំដៃគ្នាត្រឹមចុងដង្ហើម ដៃឆ្វេងលាវង់ត្រឹមចុងចញ្ចើម

- ចង្វាក់ទី១៥ : ដៃស្តាំវង់ត្រឹមចុងចិញ្ចើមដៃឆ្វេងជិតក្រោមចុងដង្ហើម

**៤. ក្បាលនិងភ្នែក** : - ចង្វាក់ទី១៣និងទី១៤ : ត្រង់

- ចង្វាក់ ទី១៥ : ផ្ទៀងឆ្វេងងាកឆ្វេង ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១៣



ចង្វាក់ទី១៤



ចង្វាក់ទី១៥



www.elibraryofcambodia.org

## ចង្វាក់ទី ១៦ : រាំលោតក្រៅអង្រែ ២ចង្វាក់ឆ្វេងមួយគ្នា ក្នុងអង្រែ១ចង្វាក់

**១. ជើង :** - ចង្វាក់ទី១៦ : ជើងឆ្វេងលោតក្រៅអង្រែឆ្វេង ក្រោមស្តាំលើកជំទើត ( ក្រៅអង្រែ)

- ចង្វាក់ទី១៧ : ស្តាំក្រោម ឆ្វេងលើកជំទើត ( ក្រៅអង្រែ)

-ចង្វាក់ទី១៨ : ឆ្វេងក្រោមស្តាំលើកពាក់កណ្តាលស្មងជើង ( ក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី១៦និងទី១៧ : ត្រង់

- ចង្វាក់ទី១៨ : ផ្ទៀងស្តាំងាកឆ្វេង

**៣. ដៃ :** - ចង្វាក់ទី១៦ : ដៃឆ្វេងជីព ស្តាំវង់ក្រោមចុងដង្ហើម

- ចង្វាក់ទី១៧ : ដៃឆ្វេងជីពមូលបំរុងលាលើចុងដង្ហើមដៃស្តាំវង់ផ្កា មូលបំរុងជីពក្រោមចុងដង្ហើម

- ចង្វាក់ទី១៨ : ដៃឆ្វេងលាវង់ត្រឹមចុងចិញ្ចើមដៃស្តាំជីពក្រោមចុងដង្ហើម

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី១៦និងទី១៧ : ត្រង់

- ចង្វាក់ទី១៨ : ផ្ទៀងស្តាំងាកឆ្វេង ភ្នែកសំឡឹងគូរាំ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១៦



ចង្វាក់ទី១៧



ចង្វាក់ទី១៨



www.elibraryofcambodia.org

## ចង្វាក់ទី ១៩ : រាំលោតក្រៅអង្រែ២ចង្វាក់ស្ដាំដៃគ្នាក្នុងអង្រែ១ចង្វាក់ស្រីបែរក្នុង ប្រុសបែរក្រៅ ឆ្វេងដៃគ្នា

**១. ជើង :** - ចង្វាក់ទី១៩ : ជើងស្ដាំលោតក្រៅអង្រែស្ដាំក្រោម ឆ្វេងលើកបោះមកក្រោយ (ក្រៅ)

- ចង្វាក់ទី២០ : ឆ្វេងក្រោម ស្ដាំលើកជំទើត (ក្រៅអង្រែ)

- ចង្វាក់ទី២១ : ស្ដាំក្រោម ជើងឆ្វេងលើកពាក់កណ្ដាលស្មងជើង (ក្នុង)

**២. ដងខ្លួននិងចង្កេះ :** ស្រីបែរមុខមកក្នុង ប្រុសបែមុខទៅក្រៅ

- ចង្វាក់ទី១៩និងទី២០ : ត្រង់

- ចង្វាក់ទី២១ : ផ្ទៀងឆ្វេងងាកស្ដាំ

**៣. ដៃ :** - ចង្វាក់ទី១៩ : ដៃទាំងពីរជីពត្រឹមចង្កេះ

- ចង្វាក់ទី២០ : ដៃទាំងពីរជីពមូលបំរុងលោត្រឹមចង្កេះ

- ចង្វាក់ទី២១ : ដៃទាំងពីរច្រត់ក្រោមចង្កេះបន្តិច

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី១៩និងទី២០ : ត្រង់

- ចង្វាក់ទី២១ : ផ្ទៀងឆ្វេងងាកស្ដាំ ភ្នែកសំឡឹងគូ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី១៩



ចង្វាក់ទី២០



ចង្វាក់ទី២១



www.elibraryofcambodia.org

## ចង្វាក់ទី ២២ : រាំលោតត្រឡប់ក្រោយកន្ទុះជុំវិញស្ដាំមកឆ្វេងរាំទល់មុខស្ដាំផែគ្នា

## ក្រៅអង្រែ២ចង្វាក់ហើយបែរខ្នងទោះជើង ឆ្វេងក្នុងអង្រែ១ចង្វាក់នៅស្ដាំផែគ្នា

១. **ជើង** : - ចង្វាក់ទី២២ : ជើងឆ្វេងលោតបោះមកក្រោយទម្ងន់ដងខ្លួនលើជើងឆ្វេងជើងស្ដាំលើក ( ក្រៅ)

- ចង្វាក់ទី២៣ : ជើងស្ដាំក្រោម ជើងឆ្វេងលើក( ក្រៅអង្រែ)

- ចង្វាក់ទី២៤ : ជើងឆ្វេងលោតបោះមកក្រោយក្នុងអង្រែបែរខ្នងដាក់គ្នាបញ្ឆិតនៅស្ដាំដៃគ្នា ជើងស្ដាំលើកពាក់កណ្ដាលស្មងជើង ( ក្នុងអង្រែ)

២. **ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី២២និងទី២៣ : ត្រង់

- ចង្វាក់ទី២៤ : ផ្ទៀងស្ដាំងាកឆ្វេង

៣. **ដៃ** : - ចង្វាក់ទី២២ : ដៃឆ្វេងជីព ដៃស្ដាំលាវង់ក្រោមចុងដងើម

- ចង្វាក់ទី២៣ : ដៃឆ្វេងជីពមូលបំរុងលាដៃស្ដាំលាមូលបំរុងទះជាមួយគូរាំត្រឹមចង្កេះ

- ចង្វាក់ទី២៤ : ដៃឆ្វេងលាវង់ត្រឹមចុងចិញ្ចើម ដៃស្ដាំលូកចាប់ដៃជាមួយគូរាំត្រឹមចង្កេះ

៤. **ក្បាលនិងភ្នែក** : - ចង្វាក់ទី២២និងទី២៣ : ត្រង់

- ចង្វាក់ទី២៤ : ផ្ទៀងស្ដាំងាកឆ្វេង ភ្នែកសំឡឹងគូ

៥. **មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី២២



ចង្វាក់ទី២៣



ចង្វាក់ទី២៤



www.elibraryofcambodia.org

**ចង្វាក់ទី ៦៥ : រាំលោតក្រៅអង្រែបង្វិលត្រឡប់ខ្លួនកន្លះជុំពីឆ្វេងមកស្តាំទល់មុខគ្នា នៅឆ្វេងវិញ ៣ចង្វាក់**

**១. ជើង** : - ចង្វាក់ទី២៥ : ជើងស្តាំមុខ ជើងឆ្វេងក្រោយបោះមកក្រោយ (ក្រៅអង្រែ)

- ចង្វាក់ទី២៦ : ជើងស្តាំវិលកន្លះជុំ ជើងឆ្វេងដកជំទើតស្មើគ្នាពេលវិលហើយ (ក្រៅអង្រែ)

- ចង្វាក់ទី២៧ : ដកជើងស្តាំមកក្រោយទប់ទម្ងន់ ឆ្វេងលើកពាក់កណ្តាលស្មងជើង (ក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី២៥និងទី២៦ : ត្រង់

- ចងវាក់ទី២៧ច : ផ្ទៀងឆ្វេងងាកឆ្វេង

**៣. ដៃ** : - ចង្វាក់ទី២៥ : ទម្លាក់ដៃស្តាំត្រឹមចង្កេះចាប់ដៃគ្នាជាមួយគូរាំ ឆ្វេងលាវង់ត្រឹមចុងចញ្ចើម

- ចង្វាក់ទី២៦ : ដៃស្តាំចាប់ដៃគ្នា ត្រឹមចុងដង្ហើមលាវង់ត្រឹមចុងចញ្ចើម

- ចង្វាក់ទី២៧ : ដៃស្តាំវង់ត្រឹមចុងចិញ្ចើម ដៃឆ្វេងជិតក្រោមចុងដង្ហើម

**៤. ក្បាលនិងភ្នែក** : - ចង្វាក់ទី២៥និងទី២៦ : ត្រង់

- ចង្វាក់ទី២៧ : ផ្ទៀងឆ្វេងងាកឆ្វេង ភ្នែកសំឡឹងគូ

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី២៥



ចង្វាក់ទី២៦



ចង្វាក់ទី២៧



www.elibraryofcambodia.org

## ចង្វាក់ទី ១៨ : រាំលោតក្រៅអង្រែ២ចង្វាក់ឆ្វេងម្ដងម្ខាង ក្នុងអង្រែ១ចង្វាក់ស្ដាំម្ដង
## ស្រីបែរទៅក្នុងប្រុសបែរមុខទៅក្រៅ

**១. ជើង :** - ចង្វាក់ទី២៨ : ជើងឆ្វេងលោតក្រៅអង្រែ ឆ្វេងក្រោម ស្ដាំលើកជំទើតកែង ( ខាងក្រៅអង្រែ)

- ចង្វាក់ទី២៩ : ជើងស្ដាំក្រោម ជើងឆ្វេងលើកជំទើត ( ក្រៅអង្រែ)

- ចង្វាក់ទី៣០ : ឆ្វេងក្រោម ជើងស្ដាំលើកពាក់កណ្ដាលស្មងជើង ( ក្នុងអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី២៨និងទី២៩ : ត្រង់

- ចង្វាក់ទី៣០ : ផ្សៀងស្ដាំងាកស្ដាំ

**៣. ដៃ :** - ចង្វាក់ទី២៨ : ទម្លាក់ដៃស្ដាំទទឹម ដៃឆ្វេងជីពក្រោមចុងដង្ហើម

- ចង្វាក់ទី២៩ : ដៃឆ្វេងជីពអូសឡើងលើត្រឹមថ្ងាស ដៃស្ដាំមូលបំរុងជីពក្រោមចុងដង្ហើម

- ចង្វាក់ទី៣០ : ដៃឆ្វេងលាវង់ត្រឹមចុងចិញ្ចើម ដៃស្ដាំជីពក្រោមចុងដង្ហើម

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី២៨និង២៩ : ត្រង់

- ចង្វាក់ទី៣០ : ផ្សៀងស្ដាំងាកស្ដាំ ភ្នែកសំឡឹងគូ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី២៨



ចង្វាក់ទី២៩



ចង្វាក់ទី៣០



www.elibraryofcambodia.org

## ចង្វាក់ទី ៣១ : រាំលោតក្រៅអង្រែ២ចង្វាក់ស្តាំថៃថ្លា ក្នុងអង្រែ១ចង្វាក់ឆ្វេងថៃថ្លា

## ស្រីបែរមកក្រៅប្រុសបែរមុខក្នុង

**១. ជើង :** - ចង្វាក់ទី៣១ : ជើងស្តាំលោតក្រៅអង្រែស្តាំក្រោម ឆ្វេងលើកជំទើត ( ខាងក្រៅអង្រែ)

- ចង្វាក់ទី៣២ : ឆ្វេងក្រោម ស្តាំលើកជំទើត ( ក្រៅអង្រែ)

- ចង្វាក់ទី៣៣ : ស្តាំក្រោម ជើងឆ្វេងលើកពាក់កណ្តាលស្មងជើង ( ក្នុងអង្រែ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៣១និងទី៣២ : ត្រង់

- ចង្វាក់ទី៣៣ : ផ្សៀងឆ្វេងងាកស្តាំ

**៣. ដៃ :** - ចង្វាក់ទី៣១ : ដៃទាំងពីរជីពត្រឹមចង្កេះ

- ចង្វាក់ទី៣២ : ដៃទាំងពីរជីពមូលបំរុងលាត្រឹមចង្កេះ

- ចង្វាក់ទី៣៣ : ដៃទាំងពីរច្រត់ក្រោមចង្កេះបន្តិច

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៣១និងទី៣២ : ត្រង់

- ចង្វាក់ទី៣៣ : ផ្សៀងឆ្វេងងាកស្តាំ ភ្នែកសំឡឹងគូ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៣១



ចង្វាក់ទី៣២



ចង្វាក់ទី៣៣



www.elibraryofcambodia.org

**ចង្វាក់ទី ៣៩ : រាំលោតត្រឡប់ក្រោយកន្ទះជុំពីស្តាំមកឆ្វេង រាំចល់ចុងស្តាំថែគ្នាក្រៅអង្រែ២ចង្វាក់ ហើយបែរខ្នងបោះជើង ក្នុងអង្រែ ១ចង្វាក់នៅស្តាំថែគ្នា**

**១. ជើង** : - ចង្វាក់ទី៣៤ : លោតបោះជើងឆ្វេងមកក្រោយក្រៅអង្រែ ឆ្វេងក្រោមស្តាំលើកជំទើត (ក្រៅអង្រែ)

- ចង្វាក់ទី៣៥ : ស្តាំក្រោមឆ្វេងលើកជំទើត (ក្រៅអង្រែ)

- ចង្វាក់ទី៣៦ : លោតជើងឆ្វេងបោះមកក្រោយក្នុងអង្រែ បែខ្នងដាក់គ្នាបញ្ឆិតទៅស្តាំដៃគ្នាជើងស្តាំលើកពាក់កណ្តាលស្មងជើង (ក្នុងអង្រែ)

**២. ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី៣៤និងទី៣៥ : ត្រង់

- ចង្វាក់ទី៣៦ : ផ្ទៀងស្តាំងាកស្តាំ

**៣. ដៃ** : - ចង្វាក់ទី៣៤ : ដៃឆ្វេងជីព ដៃស្តាំលាវង់ក្រោម (ក្រៅអង្រែ)

- ចង្វាក់ទី៣៥ : ដៃឆ្វេងជីពមូល បំរុងលាត្រឹមចុងដង្ហើម ដៃស្តាំលាមូលបំរុងលូក ទះដៃគ្នាជាមួយគូរាំត្រឹមចង្កេះ

- ចង្វាក់ទី៣៦ : ដៃឆ្វេងលាវង់ ត្រឹមចុងចិញ្ចើម ដៃស្តាំលូកទះគ្នាជាមួយគូរាំត្រឹមចង្កេះ

**៤. ក្បាលនិងភ្នែក** : - ចង្វាក់ទី៣៤និងទី៣៥ : ត្រង់

- ចង្វាក់ទី៣៦ : ផ្ទៀងស្តាំងាកស្តាំ ភ្នែកសំឡឹងគូ

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៣៤



ចង្វាក់ទី៣៥



ចង្វាក់ទី៣៦



www.elibraryofcambodia.org

## ចង្វាក់ទី ១៩ : រាំក្រៅអង្រែលោតត្រឡប់ខ្លួនកន្លះជុំរាំទីឆ្វេងមកស្តាំទល់មុខគ្នា

## ទៅឆ្វេងបែគ្នាវិញ ៣ចង្វាក់

**១. ជើង** : - ចង្វាក់ទី៣៧ : ជើងស្តាំមុខ ជើងឆ្វេងក្រោយជំទើតទាំងពីរ ទម្ងន់មុខ ( ក្រៅអង្រែ)

- ចង្វាក់ទី៣៨ : ជើងស្តាំវិលកន្លះជុំ ជើងឆ្វេងដកជំទើតស្មើគ្នាពេលវិលហើយ ( ក្រៅអង្រែ)

- ចង្វាក់ទី៣៩ : ហើយដកជើងស្តាំមកក្រោយទប់ទម្ងន់ ឆ្វេងលើកពាក់កណ្តាលស្មងជើង ( ក្រៅអង្រែ)

**២. ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី៣៧និងទី៣៨ : ផ្ទៀងស្តាំ

- ចង្វាក់ទី៣៩ : ផ្ទៀងឆ្វេងងាកឆ្វេង

**៣. ដៃ** : - ចង្វាក់ទី៣៧ : ដៃស្តាំលាចាប់ដៃគ្នាជាមួយគូរាំ ដៃឆ្វេងលើកត្រឹមចុងចិញ្ចើម

- ចង្វាក់ទី៣៨ : ដៃស្តាំលាចាប់ដៃគ្នា ដៃឆ្វេងលាវង់ត្រឹមចុងចញ្ចើម

- ចង្វាក់ទី៣៩ : ដៃស្តាំលើលាត្រឹមចុងចិញ្ចើម ដៃឆ្វេងជីពក្រោមចុងដង្ហើម

**៤. ក្បាលនិងភ្នែក** : - ចង្វាក់ទី៣៧និងទី៣៨ : ផ្ទៀងស្តាំងាកស្តាំ

- ចង្វាក់ទី៣៩ : ផ្ទៀងឆ្វេងងាកឆ្វេង ភ្នែកសំឡឹងគូ

**៥. មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៣៧



ចង្វាក់ទី៣៨



ចង្វាក់ទី៣៩



www.elibraryofcambodia.org



ចង្វាក់ទី៣៧



ចង្វាក់ទី៣៨



ចង្វាក់ទី៣៩



www.elibraryofcambodia.org

ចង្វាក់ទី ៤០ : រាំលោតក្រៅអង្រៃ២ចង្វាក់ឆ្វេងបៃធ្លា ក្នុងអង្រៃ១ចង្វាក់ ស្រីបែរមុខមកក្រៅ ប្រុសបែរមុខ មកក្នុងស្តាំបៃធ្លា

១. ជើង : - ចង្វាក់ទី៤០ : ជើងឆ្វេងលោតក្រៅអង្រៃឆ្វេងក្រោម ជើងស្តាំលើកជំទើត (ក្រៅអង្រៃ)

- ចង្វាក់ទី៤១ : ស្តាំក្រោម ឆ្វេងលើកជំទើត (ក្រៅអង្រៃ)

- ចង្វាក់ទី៤២ : ឆ្វេងក្រោម ជើងស្តាំលើកពាក់កណ្តាលស្មងជើង (ក្នុងអង្រៃ)

២. ដងខ្លួននិងចង្កេះ : - ចង្វាក់ទី៤០និងទី៤១ : ត្រង់

- ចង្វាក់ទី៤២ : ផ្ទៀងស្តាំងាកឆ្វេង

៣. ដៃ : - ចង្វាក់ទី៤០ : ដៃឆ្វេងជីព ស្តាំលាវង់ក្រោមចុងដង្ហើម

- ចង្វាក់ទី៤១ : ដៃឆ្វេងជីពមូលបំរុងលាលើចុងដង្ហើម ដៃស្តាំមូលបំរុងជីពក្រោមចុងដង្ហើម

- ចង្វាក់ទី២ : ដៃឆ្វេងហេវង់ត្រឹមចុងចិញ្ចើម ដៃស្តាំជីពក្រោមចុងដង្ហើម

៤. ក្បាលនិងភ្នែក - ចង្វាក់ទី៤០និងទី៤១ : ត្រង់

- ចង្វាក់ទី៤២ : ផ្ទៀងស្តាំងាកឆ្វេង ភ្នែកសំឡឹងគូ

៥. មនោសញ្ចេតនា : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤០



ចង្វាក់ទី៤១



ចង្វាក់ទី៤២



www.elibraryofcambodia.org

**ចង្វាក់ទី ៤៣ : រាំលោតក្រៅអង្រៃ ២ចង្វាក់ ក្នុងអង្រៃ ១ចង្វាក់**

**១. ជើង :** - ចង្វាក់ទី៤៣ : ជើងស្តាំលោតក្រៅអង្រៃ ជើងស្តាំក្រោម ជើងឆ្វេងលើកជំទើត (ក្រៅអង្រៃ)

- ចង្វាក់ទី៤៤ : ជើងឆ្វេងក្រោម ជើងស្តាំលើកជំទើត (ក្រៅអង្រៃ)

- ចង្វាក់ទី៤៥ : ជើងស្តាំក្រោមជើងឆ្វេងលើកពាក់កណ្តាលស្មងជើង (ក្នុងអង្រៃ)

**២. ដងខ្លួននិងចង្កេះ :** - ចង្វាក់ទី៤៣និងទី៤៤ : ត្រង់

- ចង្វាក់ទី៤៥ : ផ្អៀងឆ្វេងងាកស្តាំ

**៣. ដៃ :** - ចង្វាក់ទី៤៣ : ដៃទាំងពីរជីពត្រឹមចង្កេះ

- ចង្វាក់ទី៤៤ : ដៃទាំងពីរជីពមូលបំរុងលាត្រឹមចង្កេះ

- ចង្វាក់ទី៤៥ : ដៃទាំងពីរច្រត់ក្រោមចង្កេះបន្តិច

**៤. ក្បាលនិងភ្នែក :** - ចង្វាក់ទី៤៣និងទី៤៤ : ត្រង់

- ចង្វាក់ទី៤៥ : ផ្អៀងឆ្វេងងាកស្តាំ ភ្នែកសំឡឹងគូ

**៥. មនោសញ្ចេតនា :** សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤៣



ចង្វាក់ទី៤៤



ចង្វាក់ទី៤៥



www.elibraryofcambodia.org

**ចង្វាក់ទី ៩៦ : រាំលោតត្រឡប់ក្រោយកន្ត្រះជុំវិញស្តាំចុកឆ្វេងរាំទល់មុខស្តាំដៃផ្កាក្រៅអង្រែ ២ចង្វាក់ ហើយបែរខ្លួនបោះជើងឆ្វេងក្នុងអង្រែចុះយនៅស្តាំដៃផ្កា**

១. **ជើង** : - ចង្វាក់ទី៤៦ : លោតបោះជើងឆ្វេងមកក្រោយក្រៅអង្រែឆ្វេងក្រោម ស្តាំលើកជំទើត (ក្រៅអង្រែ)

- ចង្វាក់ទី៤៧ : ស្តាំក្រោម ឆ្វេងលើកជំទើត (ក្រៅអង្រែ)

- ចង្វាក់ទី៤៨ : លោតជើងឆ្វេងបោះមកក្រោយក្នុងអង្រែ ជើងស្តាំលើកពាក់កណ្តាលខ្នងជើង (ក្នុងអង្រែ)

២. **ដងខ្លួននិងចង្កេះ** : - ចង្វាក់ទី៤៦និងទី៤៧ : ត្រង់

- ចង្វាក់ទី៤៨ : ផ្ទៀងស្តាំងាកឆ្វេង

៣. **ដៃ** : - ចង្វាក់ទី៤៦ : ដៃឆ្វេងជីព ដៃស្តាំលាក្រោមចុងជង្ហើម

- ចង្វាក់ទី៤៧ : ដៃឆ្វេងជីពមូលបំរុងលា ដៃស្តាំមូលបំរុងចាប់ដៃផ្កាជាមួយគូរាំ

- ចង្វាក់ទី៤៨ : ដៃឆ្វេងលាវង់ត្រឹមចុងចិញ្ចើម ដៃស្តាំលូកចាប់ដៃផ្កាជាមួយគូរាំត្រឹមចង្កេះ

៤. **ក្បាលនិងភ្នែក** : -ចង្វាក់ទី៤៦និងទី៤៧ : ត្រង់

-ចង្វាក់ទី៤៨ : ផ្ទៀងស្តាំងាកឆ្វេង ភ្នែកសំឡឹងគូ

៥. **មនោសញ្ចេតនា** : សប្បាយរីករាយ



www.elibraryofcambodia.org



ចង្វាក់ទី៤៦



ចង្វាក់ទី៤៧



ចង្វាក់ទី៤៨



www.elibraryofcambodia.org

# ក្រឡារបាំ



ក្រឡាទី១ : អង្រែបញ្ឈរទល់នឹងចង្កេះប្រុសៗអ្នកគោះ



www.elibraryofcambodia.org



ក្រឡាទី២

អង្រែទាំងអស់ត្រូវផ្តេកទន្ទឹមគ្នា ចុះក្រោមស្របគ្នា

ស្រីៗបែរមុខដើរចេញទៅឆ្វេង ប្រុសៗត្រូវបែរមុខមកខាងស្តាំទាំងអស់គ្នា

ចាប់ផ្តើមគោះអង្រែពីរដងពេលអង្រែបើក ទង្គិចអង្រែម្តងទៀតពេលបិទ





www.elibraryofcambodia.org

# ក្រឡាក្បួនក្បាច់ទក្ខទី១






www.elibraryofcambodia.org



ចង្វាក់ ៤. ៥. ៦





www.elibraryofcambodia.org



ចង្វាក់ ៧. ៨. ៩





www.elibraryofcambodia.org



ចង្វាក់ ១០. ១១. ១២





www.elibraryofcambodia.org



ចង្វាក់ ១៣. ១៤. ១៥





www.elibraryofcambodia.org



ចង្វាក់ ១៦. ១៧. ១៨






www.elibraryofcambodia.org



ចង្វាក់ ១៩. ២០. ២១





www.elibraryofcambodia.org



ចង្វាក់ ២២. ២៣. ២៤





www.elibraryofcambodia.org



ចង្វាក់ ២៥. ២៦. ២៧





www.elibraryofcambodia.org



ចង្វាក់ ២៨. ២៩. ៣០





www.elibraryofcambodia.org



លំហាត់ ៣១. ៣២. ៣៣





www.elibraryofcambodia.org



ចង្វាក់ ៣៤. ៣៥. ៣៦





www.elibraryofcambodia.org



ចង្វាក់ ៣៧. ៣៨. ៣៩





www.elibraryofcambodia.org



ចង្វាក់ ៤០. ៤១. ៤២





www.elibraryofcambodia.org



ចង្វាក់ ៤៣. ៤៤. ៤៥





www.elibraryofcambodia.org



ចង្វាក់ ៤៦. ៤៧. ៤៨



**ចប់វគ្គទី ១**



www.elibraryofcambodia.org

www.elibraryofcambodia.org

# ក្រឡាក្នុងក្បាច់វគ្គទី២






www.elibraryofcambodia.org



ចង្វាក់ ៤. ៥. ៦





www.elibraryofcambodia.org



លំហាត់ ៧. ៨. ៩





www.elibraryofcambodia.org



ចង្វាក់ ១០. ១១. ១២





www.elibraryofcambodia.org



ចង្វាក់ ១៣. ១៤. ១៥





www.elibraryofcambodia.org



ចង្វាក់ ១៦. ១៧. ១៨





www.elibraryofcambodia.org



ចង្វាក់ ១៩. ២០. ២១



www.elibraryofcambodia.org



ចង្វាក់ ២២. ២៣. ២៤





www.elibraryofcambodia.org



ចង្វាក់ ២៥. ២៦. ២៧



www.elibraryofcambodia.org



ចង្វាក់ ២៨. ២៩. ៣០



www.elibraryofcambodia.org



ចង្វាក់ ៣១. ៣២. ៣៣





www.elibraryofcambodia.org








www.elibraryofcambodia.org



ចង្វាក់ ៣៧. ៣៨. ៣៩



www.elibraryofcambodia.org



ចង្វាក់ ៤០. ៤១. ៤២





www.elibraryofcambodia.org



ចង្វាក់ ៤៣. ៤៤. ៤៥





www.elibraryofcambodia.org



ចង្វាក់ ៤៦. ៤៧. ៤៨



**ចប់វគ្គទី ២**



www.elibraryofcambodia.org

## បទឱ្យផ្ទៃស្រុកខ្មែរ



## បទបើនាងបុកស្រូវ





www.elibraryofcambodia.org

# ទំនុកច្រៀងរបាំគោះអង្រែ

## បទឱផ្ទៃស្រុកខ្មែរ

I.  ឱផ្ទៃស្រុកខ្មែរៗ យប់ខែភ្លឺថ្លា    អ្នកស្រុកធ្វើការ ឱណាលោកអើយ

អ្នកស្រុកធ្វើការ  អឺៗ  ធ្វើកាគ្រប់ដៃ  ។

II.  មានជាងឈូសឈើៗ        រៀនធ្វើផ្ទះថ្មី  រីពួកស្រីៗ

ឱណាលោកអើយ រីពួកស្រីៗ អឺៗ អុំស្មៃអង្គរ  ។

III. មានជាងចម្លាក់ៗ មានអ្នកគូរស្គរ    កញ្ញារូបល្អ ឱណាលោកអើយ

កញ្ញារូបល្អ អឺៗ ផ្សៀងករវាត់ខ្នារ  ។



www.elibraryofcambodia.org

# បទសង្សារស្រុកស្រែ

*(ឮសម្លេងពីខាងក្នុង ដូរបទមុនផ្ទុកចេញ)*

I. យុវជនកម្ពុជា រួចផុតវេទនា បានមកជួបជុំ

ជីវភាពសុខដុម ភារៈដ៏ធំ ដីស្រែមិនភ្លេច ។

II. បោកបែនប្រមូល ផលស្រូវដាក់ចូល ជង្រុករួចស្រេច

ឥលូវថ្ងៃលិច ក្រោមខែភ្លឺផ្លេក រាំលេងកំសាន្ត ។

III. ឱណាឥឡូវថ្ងៃលិច ក្រោមខែភ្លឺផ្លេក រាំលេងកំសាន្ត អឺយ ។



www.elibraryofcambodia.org

# បទនាងបុកស្រូវ

I ថ្ងៃនេះយើងខ្ញុំ អឺ អឺ អឹង អើយ ក្រុមកសិករ

មានចិត្តរីករាយស្មោះស អឺ .... អើយ ច្រៀងរាំអង្រែ ។

II ជូនរបាំជាតិ អឺ អឺ អឹង អើយ ដំណែលជាតិខ្មែរ

យើងនាំគ្នារក្សាថែ អឺ .... អើយ កេរពីដូនតា ។

III ប្រជាកសិករ អឺ អឺ អឹង អើយ ជាជាតិខេមរា

យើងរួប យើងរួមគ្នា អឺ .... អើយ ដាំផលដំណាំ ។

IV យើងរួមសាមគ្គី អើ ធ្វើកសិកម្ម អឺ ធ្វើស្រែរាល់ឆ្នាំ

អឺ .... បង្កើនសេដ្ឋកិច្ច ។



www.elibraryofcambodia.org

# បទភ្លេងជូនឃុំកោះអំព្រៅ






www.elibraryofcambodia.org





www.elibraryofcambodia.org

# ឯកសារពិគ្រោះ

ក្នុងការចងក្រងឯកសាររបាំនេះ យើងខ្ញុំជាសិល្បករ-សិល្បការិនី ក្នុងក្រុមជំនាញស្រាវជ្រាវនៃនាយកដ្ឋានសិល្បៈ ទស្សនីយភាព បានចុះទៅប្រមូលពត៌មានដោយផ្ទាល់ពីលោកព្រឹទ្ធាចារ្យនិងគ្រូសិល្បៈចាស់ៗដែលមានការយល់ដឹង និងមានបទពិសោធន៍ដ៏ជ្រាលជ្រៅលើវិស័យសិល្បៈ វប្បធម៌ និងរបាំប្រពៃណីខ្មែរយើង ។

លោកគ្រូចាស់ទុំ ដែលបានចំណាយពេលវេលា ព្រមទាំងកម្លាំងកាយ កម្លាំងចិត្តយ៉ាងច្រើនលើសលប់ក្នុងការជួយរៀបចំចងក្រងឯកសាររបាំនេះគឺ ក្នុងបំណងជួយឱ្យស្នាដៃនេះ កាន់តែមានសុក្រឹតភាព និងបានជាប្រយោជន៍ច្រើនយ៉ាង ដល់ជនានុជនយើង ដូចមាន រាយនាមខាងក្រោម :

| | |
|---|---|
| លោកព្រឹទ្ធាចារ្យ | **ឆេង ផុន** |
| ឯកឧត្តម | **ពេជ្រ ទុំក្រវិល** |
| ឯកឧត្តម | **ហង្ស សុត** |
| លោកសាស្ត្រាចារ្យ | **ហ៊ុន សារិន** |

ដើម្បីបន្តជួយថែរក្សាមត៌កអក្សរសាស្ត្រជាតិ យើងខ្ញុំព្យាយាមរក្សាពាក្យពេចន៍ និងអក្ខរាវិរុទ្ធដោយគោរពតាមវចនានុក្រមខ្មែររបស់សម្តេច ព្រះសង្ឃរាជ **ជួន ណាត** ដែលបានបោះពុម្ពគ្រាទី៥ ក្រោមការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស ២៥១១ - គ.ស ១៩៦៧។



www.elibraryofcambodia.org

**ក្រុមសរសេរអត្ថបទ**

អ្នកស្រី ម៉ែម ស៊ីណារ៉េត – កញ្ញា ណុប ធីតា – លោក ស៊ុំ ចាន់ធឿន

**កែសម្រួលអត្ថបទ-ពិនិត្យអក្ខរាវិរុទ្ធ**

សួន ប៊ុនរិទ្ធ

**បកប្រែភាសា**

សួន ប៊ុនរិទ្ធ និង ម៉ែន ប្រាជ្ញ វុទ្ធី

**សរសេរអក្សរផ្ចង់**

លោក សាស្ត្រាចារ្យ ហ៊ុន សារិន និង ជួប សុភាព

**ជំនួយការនិទាន**

អ៊ិត ចំរើន – ឈន សំអាត

**គូរក្រឡា**

លោក អន ណាហេង – យឹម សែម

**ជំនួយការបច្ចេកទេស**

សុខ ទង – អាងគីមអ៊ិរម៉ែម ស៊ីណារ៉េត – ណុប ធីតា

**គូររូបភាព**

គីម អ៊ីលីដា – ប្រាក់ ស៊ីផាន់ណារ៉ាត

**រៀបរៀងតំរុំ**

កោ បូរិន

**អ្នកថាយអត្ថបទ**

ម៉ែន ប្រាជ្ញ វុទ្ធី – គង់ សុខ ហេង

**ថតរូប**

ណុប សំរួណា

**សិល្បៈករគ្នូរូប**

ទិន ដាណែត – នេត្រ វ៉ាន់នី – លឹម ម៉ាឡា – វ៉ា ស៊ីរិន – ពេជ្រ គន្ធារី – យឹម ចន្ទី – យឹម ស៊ីណាត

ឈឹម ណាលីន -ស៊ុនចាន់ សូ ឌីតា – គង់ វ៉ាសនា – ម៉ែន ចាន់ណារី – មឿង សារី – ដាញ់ ដារុំធ – ប៊ុត ចាន់ណោ

ឯម មេពសោភា – ណុប សំអឿន – មាស គីមហ៊ាន – សោម សុផល – អ៊ុន ដារី – អាង គីមអ៊ីរ

ម៉ៅ វុទ្ធី – មិញ យន – ហ៊ុល ចំរើន – តាំង គីមសួរ – មូល កិត្តិនាម-យឹម សែម-សឿ វុទ្ធី

**គ្រឹះស្ថានបោះពុម្ពចិន្ដ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ**



www.elibraryofcambodia.org

UNESCO

PHNOM PENH

FIRST PRINTING 1000 COPIES
SUPPORTED BY UNESCO
OCTOBER 2003

www.elibraryofcambodia.org

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ ជួន ពៅធីតា

មេសា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្លៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org